ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

អង្គជំនុំជម្រះតុលាការកំពូល
Supreme Court Chamber
Chambre de la Cour suprême

សំណុំរឿងលេខ:០០២/១៩-កញ្ញា-២០០៧-អ.វ.ត.ក-អ.ជ.ស.ដ/អ.ជ.ត.ក(០៩)
Case File/Dossier N°. 002/19-09-2007-ECCC-TC/SC(09)

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 14 / 12 / 2011
ម៉ោង (Time/Heure) : 18 : 10
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

| | |
|---|---|
| នៅចំពោះមុខ៖ | ចៅក្រម គង់ ស្រីម ប្រធាន |
| | ចៅក្រម **Motoo NOGUCHI** |
| | ចៅក្រម សោម សិរីវឌ្ឍ |
| | ចៅក្រម **Agnieszka KLONOWIECKA-MILART** |
| | ចៅក្រម ម៉ុង មុនីចរិយា |
| | ចៅក្រម **Chandra Nihal JAYASINGHE** |
| | ចៅក្រម យ៉ា ណារិន |
| កាលបរិច្ឆេទ៖ | ថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១១ |
| ភាសា | អង់គ្លេស/ខ្មែរ |
| ចំណាត់ថ្នាក់ឯកសារ៖ | សាធារណៈ: |

# សេចក្តីសម្រេចលើបណ្តឹងសាទុក្ខឆ្លាមៗប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ដែលបង្គាប់ឲ្យដោះលែងជនជាប់ចោទ អៀង ធីរិទ្ធ

| សហព្រះរាជអាជ្ញា | មេធាវីជនជាប់ចោទ | សហមេធាវីនាំមុខតំណាង |
|---|---|---|
| ជា លាង | សុន អរុណ | ដើមបណ្តឹងរដ្ឋប្បវេណី |
| Andrew CAYLEY | Michiel PESTMAN | |

**<u>ជនជាប់ចោទ</u>**

នួន ជា

អៀង សារី

អៀង ធីរិទ្ធ

ខៀវ សំផន

Victor KOPPE

អាង ឧត្តម

Michael G. KARNAVAS

ផាត់ ពៅស៊ាង

Diana ELLIS, QC

គង់ សំអុន

Jacques VERGÈS

Arthur Vercken

ពេជ អង្គ

Elisabeth SIMONNEAU FORT

00759875



**អង្គជំនុំជម្រះតុលាការកំពូល** នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (“**អ.វ.ត.ក**”) បានទទួលបណ្តឹងសាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញា[1] ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងដែលបង្គាប់ឲ្យដោះលែងជនជាប់ចោទ អៀង ធីរិទ្ធ ពីមន្ទីរឃុំឃាំង អ.វ.ត.ក (“សេចក្តីសម្រេចដែលរងការជំទាស់”)[2]។

## ១. ប្រវត្តិនីតិវិធី

១ នៅក្នុងសេចក្តីសម្រេចដែលរងការជំទាស់ អង្គជំនុំជម្រះសាលាដំបូង បានសម្រេចជាឯកច្ឆ័ន្ទថាជនជាប់ចោទពុំមានសម្បទាក្នុងការចូលរួមសវនាការឡើយ ដោយបង្គាប់ឲ្យបំបែកបទចោទប្រឆាំងនឹងជនជាប់ចោទចេញពីដីកាបញ្ជូនរឿងទៅជំនុំជម្រះក្នុងសំណុំរឿង ០០២ ប្រកាសផ្អាកកិច្ចដំណើរការនីតិវិធីប្រឆាំងលើជនជាប់ចោទ និងបង្គាប់ឲ្យដោះលែងជនជាប់ចោទពីមន្ទីរឃុំឃាំងនៃ អ.វ.ត.ក ដោយអនុលោមតាមផ្នែកសម្រេចសេចក្តីដែលនៅសល់នៃសេចក្តីសម្រេចដែលរងការជំទាស់នេះ[3]។ អង្គជំនុំជម្រះសាលាដំបូងពុំមានសម្លេងគាំទ្រចំនួនបួនសម្លេងចំពោះបញ្ហាថាតើ អង្គជំនុំជម្រះសាលាដំបូងមានយុត្តាធិការក្នុងការដាក់លក្ខខណ្ឌលើការដោះលែងជនជាប់ចោទ ដែរ ឬយ៉ាងណា។ ទោះបីជាយ៉ាងណាក៏ដោយ អង្គជំនុំជម្រះសាលាដំបូងបានយល់ស្របជាឯកច្ឆ័ន្ទថា លទ្ធផលនៃការខ្វែងគំនិតគ្នាលើចំណុចនេះ គឺថាជនជាប់ចោទត្រូវដោះលែងដោយអនុលោមតាមផ្នែកសម្រេចសេចក្តីនៃសេចក្តីសម្រេចដែលរងការជំទាស់នេះ។

---

[1] បណ្តឹងសាទុក្ខភ្លាមៗប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងដែលបង្គាប់ឲ្យដោះលែងជនជាប់ចោទអៀងធីរិទ្ធថ្ងៃទី១៨ខែវិច្ឆិកាឆ្នាំ២០១១ឯកសារE138/1/1 (“បណ្តឹងសាទុក្ខភ្លាមៗ”) ។សេចក្តីសន្និដ្ឋានបន្ថែមរបស់សហព្រះរាជអាជ្ញាលើបណ្តឹងសាទុក្ខពាក់ព័ន្ធនឹងការដោះលែងជនជាប់ចោទអៀងធីរិទ្ធថ្ងៃទី២២ខែវិច្ឆិកាឆ្នាំ២០១១ឯកសារE138/1/4 (“សេចក្តីសន្និដ្ឋានបន្ថែម”)។

[2] សេចក្តីសម្រេចលើសម្បទារបស់អៀងធីរិទ្ធក្នុងការចូលរួមសវនាការឯកសារE138 ថ្ងៃទី១៧ខែវិច្ឆិកាឆ្នាំ២០១១។

[3] សេចក្តីសម្រេចដែលរងការជំទាស់ទំព័រ៣០៖

**រំលឹក**ជនជាប់ចោទនូវកាតព្វកិច្ចរបស់ខ្លួនស្របតាមវិធានផ្ទៃក្នុង៣៥ដោយមិនឲ្យជ្រៀតជ្រែករដ្ឋបាលយុត្តិធម៌ហើយជាពិសេសការទាក់ទងជាមួយសាក្សីឬសាក្សីសក្តានុពលរបស់អ.វ.ត.ក។

**បង្គាប់**ឲ្យជនជាប់ចោទជូនដំណឹងដល់អង្គជំនុំជម្រះមុននឹងប្តូរអាសយដ្ឋានទៅកន្លែងផ្សេង។

**ជម្រាប**មកសហព្រះរាជអាជ្ញាថាសហព្រះរាជអាជ្ញាអាចស្នើសុំឲ្យអង្គជំនុំជម្រះចាត់តាំងអ្នកជំនាញឲ្យធ្វើការវាយតម្លៃ អៀង ធីរិទ្ធ ឡើងវិញ តាមរយៈកាល និងអាចស្នើសុំឲ្យអង្គជំនុំជម្រះចាប់ផ្តើមដំណើរការចំពោះជនជាប់ចោទ អៀង ធីរិទ្ធ នៅដំណាក់កាលណាមួយក៏បាននៅពេលដែលមានការបង្ហាញថាស្ថានភាពសុខភាពរបស់ជនជាប់ចោទមានការផ្លាស់ប្តូរ។ ដើម្បីសម្រេចបានគោលដៅនេះសហព្រះរាជអាជ្ញាត្រូវបង្កើតយន្តការត្រួតពិនិត្យស្ថានភាពសុខភាពរបស់ជនជាប់ចោទជាប្រចាំ។

២ ក្នុងរយៈពេល ២៤ម៉ោងបន្ទាប់ពីសេចក្តីសម្រេចដែលរងការជំទាស់នេះ សហព្រះរាជអាជ្ញាបានដាក់សំណើមួយទៅប្រធានអង្គជំនុំជម្រះតុលាការកំពូលសុំផ្អាកសេចក្តីសម្រេចដោះលែង[4] ដោយភ្ជាប់ជាមួយនឹងច្បាប់ចតចម្លងនៃបណ្តឹងសាទុក្ខភ្លាមៗរបស់ខ្លួនប្រឆាំងនឹងសេចក្តីសម្រេចដោះលែង ដែលនៅក្នុងបណ្តឹងសាទុក្ខនោះ សហព្រះរាជអាជ្ញាបានសុំការអនុញ្ញាតដាក់សេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរបន្ថែម។ នៅថ្ងៃទី ១៩ ខែវិច្ឆិកា ឆ្នាំ ២០១១ ប្រធានអង្គជំនុំជម្រះតុលាការកំពូលបានផ្អាកសេចក្តីសម្រេចដោះលែងនោះ[5] ហើយនៅថ្ងៃទី ២១ ខែវិច្ឆិកា ឆ្នាំ២០១១ អង្គជំនុំជម្រះតុលាការកំពូលបានផ្តល់ការអនុញ្ញាតឱ្យសហព្រះរាជអាជ្ញាដាក់សេចក្តីសន្និដ្ឋានបន្ថែម ត្រឹមថ្ងៃទី ២២ ខែវិច្ឆិកា ឆ្នាំ២០១១។ សហព្រះរាជអាជ្ញាបានដាក់សេចក្តីសន្និដ្ឋានបន្ថែមនៅថ្ងៃទី ២២ ខែវិច្ឆិកា ឆ្នាំ២០១១ ហើយមេធាវីការពារក្តីបានដាក់សារណាតបរបស់ខ្លួននៅថ្ងៃទី ២៨ ខែវិច្ឆិកា ឆ្នាំ ២០១១[6]។

## ២. មូលដ្ឋាននៃការពិនិត្យឡើងវិញសម្រាប់បណ្តឹងសាទុក្ខភ្លាមៗ

៣ អនុលោមតាមវិធានផ្ទៃក្នុង ១០៤ (១) និង ១០៥(២) បណ្តឹងសាទុក្ខភ្លាមៗអាចផ្អែកទៅលើមូលដ្ឋានមួយឬច្រើន នៃមូលដ្ឋានបីខាងក្រោមនេះ៖

-កំហុសអង្គច្បាប់ ដែលនាំឱ្យសេចក្តីសម្រេចមោឃៈ

-កំហុសអង្គហេតុ ដែលនាំឱ្យសេចក្តីសម្រេចមានភាពមិនយុត្តិធម៌

-ការភ័ន្តច្រឡំ ដែលស្តែងចេញពីការប្រើឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូងដែលនាំឱ្យប៉ះពាល់ដល់សិទ្ធិរបស់ម្ចាស់បណ្តឹងសាទុក្ខ។

## ៣. សាវតា

៤ ដើម្បីវាយតម្លៃសម្បទារបស់ជនជាប់ចោទក្នុងការចូលរួមសវនាការ អង្គជំនុំជម្រះសាលាដំបូងបានចាត់តាំងក្រុមអ្នកជំនាញពីរក្រុមជាបន្តបន្ទាប់៖ ក្រុមទីមួយ អ្នកជំនាញផ្នែកមនុស្សចាស់ សាស្ត្រាចារ្យ A. John Campbell (អមដោយអ្នកជំនាញផ្នែកវិកលចរិត វេជ្ជបណ្ឌិត កា ស៊ុនបូណាត និងក្រុមបន្ទាប់ទៀតគឺអ្នកជំនាញបួនរូប វេជ្ជបណ្ឌិត ហួត លីនណា វេជ្ជបណ្ឌិត កើត ឈុនលី វេជ្ជបណ្ឌិត Seena Fazel និង វេជ្ជបណ្ឌិត Calvin Fones Soon Leng ដែលត្រូវបានស្នើឱ្យផ្តល់សេចក្តីសន្និដ្ឋានបន្ថែមលើ

[4] សំណើរបស់សហព្រះរាជអាជ្ញាសុំផ្អាកការដោះលែងជនជាប់ចោទអៀងធីរិទ្ធថ្ងៃទី១៨ខែវិច្ឆិកាឆ្នាំ២០១១ឯកសារE138/1/2។

[5] ដីកាសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាសុំផ្អាកសេចក្តីសម្រេចដោះលែងជនជាប់ចោទថ្ងៃទី១៩ខែវិច្ឆិកាឆ្នាំ២០១១ឯកសារE138/1/2/1។

[6] ចម្លើយតបរបស់មេធាវីការពារក្តីលោកស្រីអៀងធីរិទ្ធទៅនឹងបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងថ្ងៃទី១៧ខែវិច្ឆិកាឆ្នាំ២០១១ឯកសារE138/1/5 ("ចម្លើយតប")។

00759877



សេចក្តីសន្និដ្ឋានរបស់សាស្ត្រាចារ្យ Campbell និងផ្តល់នូវរបាយការណ៍ជំនាញឯកទេសខាងវិកលវិទ្យា។ អង្គជំនុំជម្រះសាលាដំបូងបានទទួលរបាយការណ៍បីផ្សេងគ្នាពីអ្នកជំនាញទាំងនេះ[7]។ សេចក្តីសម្រេចដែលរងការជំទាស់នេះ បានចេញបន្ទាប់ពីមានសវនាការចំនួនពីរ ដែលអនុញ្ញាតឲ្យមានការធ្វើបទបង្ហាញដោយផ្ទាល់មាត់នៃរបាយការណ៍របស់អ្នកជំនាញ និងសារណារបស់ភាគី ទាក់ទិននឹងសេចក្តីសន្និដ្ឋានរបស់ពួកគាត់។

៥ អ្នកជំនាញផ្នែកវេជ្ជសាស្ត្រទាំងប្រាំនាក់បានយល់ស្របថា ជនជាប់ចោទមានជំងឺវង្វេងស្មារតី អាចថាជាជំងឺវង្វេងវង្វាន់[8]។ នៅក្នុងរបាយការណ៍តាមដានបន្ត សាស្ត្រាចារ្យ Campbell បានផ្តល់អនុសាសន៍ឲ្យសាកល្បងប្រើថ្នាំ Donepezil ដែលជាឱសថសម្រាប់ជំងឺវង្វេងវង្វាន់ ដែលមានប្រសិទ្ធភាពចំពោះអ្នកជំងឺមួយភាគបីនៃអ្នកជំងឺដែលបានទទួលការព្យាបាល[9]។ របាយការណ៍អ្នកជំនាញផ្នែកវិកលវិទ្យាបានស្នើឡើងថា វិធានការផ្សេងៗទៀតអាចមានប្រយោជន៍ចំពោះជនជាប់ចោទ រួមមានការរក្សាចំនួនបុគ្គលិកនិងបុគ្គលិកដដែល ការរក្សាឲ្យមានបរិស្ថានដដែល ការបត់បែនដើម្បីសម្របសម្រួលទៅនឹងលទ្ធភាពប្រែប្រួលរបស់គាត់ ការធ្វើលំហាត់ប្រាណ ដោយមានការវាយតម្លៃ និងដំបូន្មានពីអ្នកឯកទេសព្យាបាលផ្នែកសរីរៈ នៅពេលដែលត្រូវការ និងការគាំទ្រដល់ការចូលរួមក្នុងសកម្មភាពដែលគាត់ពេញចិត្ត[10]។ លើសពីនេះទៀត "កម្មវិធីជំរុញសតិបញ្ញាដែលមានរចនាសម្ព័ន្ធត្រឹមត្រូវ" និងការបន្តព្យាបាលលើស្ថានភាពវេជ្ជសាស្ត្រពីរដែលមានអត្ថិភាពរួមគ្នា អាចជួយឲ្យមានលក្ខណៈល្អប្រសើរខ្លះដែរ[11]។

## ៤.សេចក្តីសម្រេចដែលរងការជំទាស់

---

[7]របាយការណ៍ដែលបានរៀបចំឡើងដើម្បីជាការឆ្លើយតបទៅនឹងដីកាចាត់តាំងអ្នកជំនាញរបស់អង្គជំនុំជម្រះសាលាដំបូង E62/3... របាយការណ៍អ្នកជំនាញផ្នែកព្យាបាលមនុស្សចាស់សម្រាប់អ្នកស្រីអៀងធីរិទ្ធចុះថ្ងៃទី២៣ខែមិថុនាឆ្នាំ២០១១,E62/3/6 ("របាយការណ៍អ្នកជំនាញផ្នែកព្យាបាលមនុស្សចាស់")។របាយការណ៍តាមដានបន្តពាក់ព័ន្ធនឹងលោកស្រីអៀងធីរិទ្ធដើម្បីគោរពតាមដីការបស់អង្គជំនុំជម្រះសាលាដំបូងបង្គាប់ចាត់តាំងអ្នកជំនាញឯកសារE62/3 ចុះថ្ងៃទី៤ខែមេសាឆ្នាំ២០១១ថ្ងៃទី២៦ខែសីហាឆ្នាំ២០១១ឯកសារE62/3/12 ("របាយការណ៍តាមដានបន្តរបស់អ្នកជំនាញផ្នែកព្យាបាលមនុស្សចាស់")។របាយការណ៍អ្នកជំនាញដែលបានរៀបចំឡើង ដើម្បីជាការឆ្លើយតបទៅនឹងដីកាចាត់តាំងអ្នកជំនាញរបស់អង្គជំនុំជម្រះសាលាដំបូងឯកសារ E111 ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១១ថ្ងៃទី៩ ខែតុលា ឆ្នាំ២០១១ ឯកសារE111/8 ("របាយការណ៍របស់អ្នកជំនាញផ្នែកវិកលវិទ្យា")។

[8]របាយការណ៍របស់អ្នកជំនាញផ្នែកព្យាបាលមនុស្សចាស់កថាខណ្ឌ៤០ ("មានជំងឺវង្វេងស្មារតីធ្ងន់ធ្ងរកម្រិតមធ្យមអាចថាជាជំងឺ វង្វេងវង្វាន់")។ របាយការណ៍រួមរបស់អ្នកជំនាញផ្នែកវិកលវិទ្យាកថាខណ្ឌ៣៦ (សម្រង់)។

[9]របាយការណ៍តាមដានបន្តកថាខណ្ឌ៨។

[10]របាយការណ៍រួមរបស់អ្នកជំនាញផ្នែកវិកលវិទ្យាកថាខណ្ឌ៣៨។

[11]របាយការណ៍រួមរបស់អ្នកជំនាញផ្នែកវិកលវិទ្យាកថាខណ្ឌ៣៨។

៦ អង្គជំនុំជម្រះសាលាដំបូងបានយល់ស្របជាមួយអ្នកជំនាញវេជ្ជសាស្ត្រដែលថា "ការបាត់បង់ការចងចាំរយៈពេលវែង និងរយៈពេលខ្លីរបស់លោកស្រី អៀង ធីរិទ្ធ ច្បាស់ជាធ្វើឲ្យជនជាប់ចោទរូបនេះមិនអាចយល់ដឹងអំពីការប្រព្រឹត្តិទៅនៃកិច្ចដំណើរការនីតិវិធីឲ្យបានគ្រប់គ្រាន់ ដើម្បីអាចឲ្យជនជាប់ចោទណែនាំមេធាវីការពារក្តីរបស់គាត់ឲ្យបានគ្រប់ជ្រុងជ្រោយ និងចូលរួមក្នុងការពារក្តីរបស់ខ្លួនឲ្យមានប្រសិទ្ធិភាពបាននោះទេ"[12]។ ដោយសារតែ "លោកស្រី អៀង ធីរិទ្ធ មិនអាចអនុវត្តសិទ្ធិជាសារវ័ន្តរបស់គាត់ក្នុងការទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ និងប្រកបដោយអត្ថន័យទាំងអស់នេះហើយ និងដោយអនុលោមទៅតាមបទដ្ឋានអន្តរជាតិដែលបានកំណត់នៅក្នុងសេចក្តីសម្រេចក្នុងរឿងក្តី *Sirugar*" ទើបអង្គជំនុំជម្រះសាលាដំបូងពិចារណាថា ខ្លួន"គ្មានជម្រើសអ្វីក្រៅពីប្រកាសថា លោកស្រីពុំមានសម្បទាក្នុងការចូលរួមសវនាការនោះទេ"[13]។ ដោយសារតែស្ថានភាពរបស់ជនជាប់ចោទ "ទំនងជានឹងបង្កភាពស្មុគស្មាញ ប៉ះពាល់ដល់សិទ្ធិរបស់ជនជាប់ចោទដទៃទៀតនៅក្នុងសំណុំរឿង ០០២ ក្នុងការទទួលបានការជំនុំជម្រះក្តីដោយឆាប់រហ័ស" ទើបអង្គជំនុំជម្រះសាលាដំបូង "សម្រេចជាឯកច្ឆ័ន្ទថា ដើម្បីប្រយោជន៍យុត្តិធម៌ អង្គជំនុំជម្រះសាលាដំបូងត្រូវបំបែកបទចោទប្រឆាំងលើជនជាប់ចោទ អៀង ធីរិទ្ធ ក្នុងសំណុំរឿង ០០២ ដោយអនុលោមទៅតាមវិធាន ៨៩ ស្ទួនពីរ និងផ្អាកកិច្ចដំណើរការនីតិវិធីលើជនជាប់ចោទ"[14]។ បន្ទាប់មកអង្គជំនុំជម្រះសាលាដំបូងបានពិចារណាទៀតថា "ដោយយោងទៅលើការរកឃើញរបស់ខ្លួនអំពីភាពគ្មានសមត្ថភាពក្នុងការចូលរួមក្នុងការជំនុំជម្រះក្តី និងការបំបែកបទចោទទាំងអស់ប្រឆាំងលើជនជាប់ចោទរូបនេះ ដោយអនុលោមទៅតាមវិធាន ៨៩ ស្ទួនពីរ និងការផ្អាកកិច្ចដំណើរការនីតិវិធីលើជនជាប់ចោទក្នុងសំណុំរឿង ០០២ នោះ អង្គជំនុំជម្រះសាលាដំបូងពុំមានមូលដ្ឋានណាមួយដើម្បីបន្តឃុំខ្លួនជនជាប់ចោទតទៅទៀត បានទេ"[15]។

៧ អង្គជំនុំជម្រះសាលាដំបូងមិនអាចស្វែងរកសម្លេងគាំទ្រ៤សម្លេង ទៅលើបញ្ហាថា តើគួរបង្គាប់ឲ្យជនជាប់ចោទ ទទួលការព្យាបាលផ្នែកវេជ្ជសាស្ត្រ ឬថាតើគួរដោះលែងជនជាប់ចោទដោយគ្មានលក្ខខណ្ឌ[16]។ មតិភាគច្រើនរបស់លោកចៅក្រម និល ណុន លោកចៅក្រម យ៉ា សុខន និងលោកចៅក្រម យូរ ឧត្តរា បានសន្និដ្ឋានថាជនជាប់ចោទគួរត្រូវបាន "ដោះលែងជាបណ្តោះអាសន្ន"[17] ដោយមាន "ភ្ជាប់លក្ខខណ្ឌជាក់

[12]សេចក្តីសម្រេចដែលរងការជំទាស់ កថាខណ្ឌ ៥៩។

[13]សេចក្តីសម្រេចដែលរងការជំទាស់ កថាខណ្ឌ ៥៩។

[14]សេចក្តីសម្រេចដែលរងការជំទាស់ កថាខណ្ឌ ៦១។

[15]សេចក្តីសម្រេចដែលរងការជំទាស់ កថាខណ្ឌ ៦១។

[16]សេចក្តីសម្រេចដែលរងការជំទាស់ កថាខណ្ឌ ៦២។

[17]សេចក្តីសម្រេចដែលរងការជំទាស់ កថាខណ្ឌ ៦៦។

លាក់មួយចំនួន"[18] ហើយផ្ទេរជនជាប់ចោទទៅកាន់មន្ទីរពេទ្យ ដើម្បីទទួលបាននូវការព្យាបាលតាមអនុសាសន៍របស់អ្នកជំនាញវេជ្ជសាស្ត្រ[19]។ មតិភាគច្រើនរបស់ចៅក្រមអង្គជំនុំជម្រះសាលាដំបូង បានសន្និដ្ឋានថា សម្បទាក្នុងការចូលរួមសវនាការរបស់ជនជាប់ចោទ គួរត្រូវបានធ្វើការវាយតម្លៃឡើងវិញ បន្ទាប់ពីទទួលបានការព្យាបាលបែបនេះរយៈពេល៦ខែ[20]។ មតិភាគច្រើនរបស់ចៅក្រមអង្គជំនុំជម្រះសាលាដំបូង បានផ្អែកទៅលើមាត្រា ២២៣(១១) នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា[21](CCP) និងយុត្តិសាស្ត្ររបស់តុលាការ ICTY[22] ធ្វើជាមូលដ្ឋានគតិយុត្ត សម្រាប់ដាក់ជនជាប់ចោទ "ឲ្យស្ថិតនៅក្រោមរបបព្យាបាលរោគនៅមន្ទីរពេទ្យជាបណ្ដោះអាសន្ន"[23]។

៨ នៅក្នុងមតិភាគតិចរបស់ចៅក្រមអង្គជំនុំជម្រះសាលាដំបូង លោកស្រីចៅក្រម Silvia CARTWRIGHT និងលោកចៅក្រម Jean-Marc LAVERGNE បានពិចារណាថាមិនមាន "មូលដ្ឋានអង្គហេតុដែលបង្ហាញថា ជនជាប់ចោទអាចធូរស្បើយនៅថ្ងៃអនាគត ដើម្បីឲ្យគាត់មានសម្បទាគ្រប់គ្រាន់ក្នុងការចូលរួមសវនាការនោះឡើយ"[24]។ មតិភាគតិចរបស់ចៅក្រមអង្គជំនុំជម្រះសាលាដំបូង បានបញ្ជាក់បន្ថែមថា "ពុំមានមូលដ្ឋានគតិយុត្តិណាមួយ ដែលតម្រូវបង្គាប់ឲ្យជនជាប់ចោទចូលសម្រាកព្យាបាលក្នុងមន្ទីរពេទ្យនោះទេ"[25]។ ជាពិសេសទៅទៀត បើយោងតាមមតិភាគតិចរបស់ចៅក្រមអង្គជំនុំជម្រះសាលាដំបូង មាត្រា ២២៣ (១១) នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា "មិនអាចអនុវត្តបានទេ នៅពេលដែលអង្គជំនុំជម្រះបានសម្រេចថា ជនជាប់ចោទណាម្នាក់គ្មានសម្បទាក្នុងការចូលរួមសវនាការ ហើយកិច្ចដំណើការនីតិវិធី

[18]សេចក្ដីសម្រេចដែលរងការជំទាស់ កថាខណ្ឌ ៦៧។

[19]សេចក្ដីសម្រេចដែលរងការជំទាស់ កថាខណ្ឌ ៦៤-៦៥។

[20]សេចក្ដីសម្រេចដែលរងការជំទាស់ កថាខណ្ឌ ៦៦។

[21]សេចក្ដីសម្រេចដែលរងការជំទាស់ កថាខណ្ឌ ៦៦។ មាត្រា២២៣(១១) នៃក្រមនិតិវិធីព្រហ្មទណ្ឌចែងថា "ការត្រួតពិនិត្យតាមផ្លូវតុលាការ មានអានុភាពបង្គាប់ជនត្រូវចោទដែលនៅក្រៅឃុំ ឲ្យគោរពកាតព្វកិច្ចមួយ ឬច្រើន៖ ត្រូវប្រគល់ខ្លួនឲ្យពេទ្យពិនិត្យព្យាបាល និងជាយថាហេតុ ដាក់ឲ្យស្ថិតនៅក្រោមរបបព្យាបាលរោគក្នុងមន្ទីរពេទ្យ"។

[22]សេចក្ដីសម្រេច កថាខណ្ឌ ៦៦ (ដកស្រង់រដ្ឋអាជ្ញាទល់នឹង*Kovačević* សំណុំរឿងលេខ IT-01-4212-1 "សេចក្ដីសម្រេចអំពីការដោះលែងជាបណ្ដោះអាសន្ន" ចុះថ្ងៃទី ០២ ខែ មិថុនា ឆ្នាំ ២០០៤។ រដ្ឋអាជ្ញាទល់នឹង*Kovačević* សំណុំរឿងលេខ IT-01-42/2-I "សេចក្ដីសម្រេចលើសំណើ របស់មេធាវីការពារក្ដីសុំបដិសេធដីកាដំណោះស្រាយ" ថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ២០០៦ កថាខណ្ឌ ២។ រដ្ឋអាជ្ញាទល់នឹង*Kovačević* សំណុំរឿងលេខ IT-01-42/2-I "សេចក្ដីសម្រេចផ្ទេរសំណុំរឿង អនុលោមតាមវិធាន ១១ ស្ទួន ដោយភ្ជាប់ឧបសម្ព័ន្ធជាសម្ងាត់" ថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០០៦ កថាខណ្ឌ ២៣ និង ៤៨)។

[23]សេចក្ដីសម្រេចដែលរងការជំទាស់ កថាខណ្ឌ ៦៦។

[24]សេចក្ដីសម្រេចដែលរងការជំទាស់ កថាខណ្ឌ ៧២។

[25]សេចក្ដីសម្រេចដែលរងការជំទាស់ កថាខណ្ឌ ៧៤។

ត្រូវបានផ្អាក"[26]។ មតិភាគតិចរបស់ចៅក្រមអង្គជំនុំជម្រះសាលាដំបូង បានពន្យល់នូវភាពខុសគ្នានៅក្នុងរឿងក្ដីនៅតុលាការ ICTY ដែលមតិភាគច្រើនរបស់ចៅក្រមអង្គជំនុំជម្រះសាលាដំបូង បានប្រើប្រាស់ជាមូលដ្ឋាន ហើយភាពខុសគ្នានោះគឺត្រង់មូលដ្ឋានថា ក្នុងរឿងក្ដីនៅតុលាការ ICTY ភាគីទាំងពីរបានឯកភាពគ្នាថា ជនជាប់ចោទ ត្រូវការចាំបាច់នូវការថែរក្សាផ្នែកវេជ្ជសាស្ត្រសង្គ្រោះបន្ទាន់[27]។ ផ្ទុយទៅវិញ ក្នុងរឿងក្ដីបច្ចុប្បន្ននេះ គឺពាក់ព័ន្ធនឹងជំងឺនៃការធ្លាក់ចុះខ្សោយផ្នែកបញ្ញាស្មារតីជាលំដាប់ ហើយជំងឺនេះទំនងជាមិនអាចមានភាពប្រសើរឡើងវិញនោះទេ ហើយមេធាវីការពារក្ដី មិនបានស្នើសុំឱ្យបញ្ជូនជនជាប់ចោទទៅព្យាបាលនៅមន្ទីរពេទ្យនោះដែរ។ មតិភាគតិចរបស់ចៅក្រមអង្គជំនុំជម្រះសាលាដំបូង បានសន្និដ្ឋានថាដំណោះស្រាយតែមួយគត់ដែលមានគឺការដោះលែងដោយគ្មានលក្ខខណ្ឌ[28]។

៩ អង្គជំនុំជម្រះសាលាដំបូង ត្រូវតែសម្រេចពីផលវិបាកនៃការមិនអាចស្វែងរកបាននូវមតិភាគច្រើនលើសលុប[29] ទៅលើបញ្ហាថា តើត្រូវមានលក្ខខណ្ឌកំណត់ភ្ជាប់ជាមួយការដោះលែងជនជាប់ចោទ ដែរ ឬយ៉ាងណា។ ដោយសារតែពុំមានគោលការណ៍ណែនាំនៅក្នុងច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក កិច្ចព្រមព្រៀង អ.វ.ត.ក ឬច្បាប់កម្ពុជា ហើយដោយសារតែមិនមានគោលការណ៍ណែនាំរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិដទៃទៀត ទើបអង្គជំនុំជម្រះសាលាដំបូង "ត្រូវរកបទប្បញ្ញត្តិទូទៅនៃច្បាប់ព្រហ្មទណ្ឌអន្តរជាតិ និងច្បាប់សិទ្ធិមនុស្ស"[30]។ ការបកស្រាយ ត្រូវតែផ្ដល់ប្រយោជន៍ដល់ជនជាប់ចោទ[31] ហើយ"សេរីភាពគឺជាវិធាន" រីឯការឃុំឃាំង "គឺជាករណីពិសេស"[32]។ លើសពីនេះទៅទៀត "ការបន្តឃុំខ្លួន ឬការដាក់ឃុំឃាំងដោយបង្ខំនៅក្នុងស្ថានភាពដែលមិនច្បាស់លាស់ ថាតើអង្គជំនុំជម្រះនឹងត្រូវធ្វើសវនាការពេលណា

[26] សេចក្ដីសម្រេច កថាខណ្ឌ ៧៤។

[27] សេចក្ដីសម្រេច កថាខណ្ឌ ៧៥។

[28] សេចក្ដីសម្រេច កថាខណ្ឌ ៧៦។

[29] ច្បាប់ស្ដីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញបូកជាមួយច្បាប់វិសោធនកម្មដែលបានប្រកាសឱ្យប្រើ ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ ២០០៤ (នស/រកម/១០០៤/០០៦) មាត្រា ១៤(១) ចៅក្រមទាំងអស់ត្រូវព្យាយាមសម្រេចឱ្យបានភាពឯកច្ឆ័ន្ទក្នុងសេចក្ដីសម្រេចរបស់ខ្លួន។ ប្រសិនបើភាពឯកច្ឆ័ន្ទនេះ ពុំអាចរកបានទេត្រូវអនុវត្តគោលការណ៍ដូចខាងក្រោម៖ ក/ ការសម្រេចសេចក្ដីដោយអង្គជំនុំជម្រះវិសាមញ្ញរបស់សាលាដំបូង តម្រូវឱ្យមានការបោះឆ្នោតគាំទ្រពីចៅក្រមបួនរូបយ៉ាងតិច។ ខ/ ការសម្រេចសេចក្ដីដោយអង្គជំនុំជម្រះវិសាមញ្ញរបស់តុលាការកំពូល តម្រូវឱ្យមានការបោះឆ្នោតគាំទ្រពីចៅក្រមប្រាំរូបយ៉ាងតិច។

[30] សេចក្ដីសម្រេច កថាខណ្ឌ ៧៩។

[31] សេចក្ដីសម្រេច កថាខណ្ឌ ៨០។

[32] សេចក្ដីសម្រេច កថាខណ្ឌ ៨០។

នោះ គឺជាការរំលោភសិទ្ធិរបស់ជនជាប់ចោទចំពោះការជំនុំជម្រះក្ដីដោយយុត្តិធម៌ និងសិទ្ធិទទួលបានសេរីភាព"[33]។ ជាចុងក្រោយ អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ថា ៖

> អវត្តមាននៃការព្រមព្រៀង អំពីលក្ខខណ្ឌចំពោះការដោះលែង គឺនាំឱ្យស្ថានភាពរបស់ជនជាប់ចោទមានភាពមិនច្បាស់លាស់។ ជាលទ្ធផលនៃសេចក្ដីសម្រេចនេះ ប្រសិនបើមាន ប្រសិនបើជនជាប់ចោទ អៀង ធីរិទ្ធ ត្រូវបានរក្សាទុកនៅក្នុងមន្ទីរឃុំឃាំងនៃ អ.វ.ត.ក ឬត្រូវដាក់ឱ្យព្យាបាលដោយបង្ខំនៅមន្ទីរពេទ្យលទ្ធភាពដែលអាចកើតមាននោះ គឺថា ការបន្តឃុំឃាំងមិនមានមូលដ្ឋានច្បាប់ទេ។ ដើម្បីកុំឱ្យមានបញ្ហានេះ អង្គជំនុំជម្រះយល់ស្របគ្នាជាឯកច្ឆ័ន្ទថា ដំណោះស្រាយតែមួយគត់នៅក្នុងស្ថានភាពនេះ គឺត្រូវដោះលែងជនជាប់ចោទដោយគ្មានលក្ខខណ្ឌ[34]។

## ៥. សារណា

១០ នៅក្នុងបណ្ដឹងសាទុក្ខភ្លាមៗរបស់ខ្លួន សហព្រះរាជអាជ្ញាស្នើថា អង្គជំនុំជម្រះតុលាការកំពូលគួរតែទុកជាមោឃៈនូវសេចក្ដីសម្រេចដែលរងការជំទាស់ ត្រង់ចំណុចដែលបង្គាប់ឱ្យដោះលែងជនជាប់ចោទ និងសុំឱ្យកែប្រែសេចក្ដីសម្រេចដែលរងការជំទាស់ ដោយបង្គាប់ឱ្យជនជាប់ចោទបន្តស្ថិតនៅក្នុងមន្ទីរឃុំឃាំង និងទទួលការព្យាបាលផ្នែកវេជ្ជសាស្ត្រ ឬវិធីកែលម្អសុខភាពផ្សេងៗទៀត ដោយត្រូវត្រួតពិនិត្យមើលក្នុងរយៈពេល ៦ ខែខាងមុខ[35]។ សហព្រះរាជអាជ្ញាបានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គច្បាប់ ដោយបង្គាប់ឱ្យសហព្រះរាជអាជ្ញា "ត្រូវបង្កើតយន្តការត្រួតពិនិត្យស្ថានភាពសុខភាពរបស់ជនជាប់ចោទជាប្រចាំ"[36]។ បើតាមទស្សនៈរបស់សហព្រះរាជអាជ្ញា សេចក្ដីណែនាំបែបនេះធ្វើឡើងដោយពុំមានមូលដ្ឋានផ្លូវច្បាប់ទេ។ ទីពីរ សហព្រះរាជអាជ្ញាលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គច្បាប់ និងអង្គហេតុ និង បានរំលោភបំពានលើអំណាចឆន្ទានុសិទ្ធិរបស់ខ្លួន ដោយសន្និដ្ឋានថា "ពុំមានមូលដ្ឋានអ្វីដែលត្រូវឃុំឃាំងជនជាប់ចោទទៀតទេ"។ អង្គជំនុំជម្រះសាលាដំបូងខកខានមិនបានពិនិត្យពិភាក្សាទៅលើវិធានផ្ទៃក្នុងដែលគ្រប់គ្រងដោយការឃុំខ្លួនបណ្ដោះអាសន្ន រួមមានវិធាន ៨២(១) ដែលមានចែងពីវិធានស្ដីពីសេចក្ដីសម្រេចដែលមិនមានសម្លេងគាំទ្រគ្រប់គ្រាន់ថា ជនជាប់ចោទនឹងត្រូវបន្ត

[33] ប្រសិនបើជាលទ្ធផលនៃសេចក្ដីសម្រេចនេះ (ជនជាប់ចោទ អៀង ធីរិទ្ធ ត្រូវបាន រក្សាទុកនៅមន្ទីរឃុំឃាំងរបស់ អ.វ.ត.ក ឬ ដាក់ឱ្យព្យាបាលដោយបង្ខំនៅមន្ទីរពេទ្យលទ្ធភាព ដែលអាចកើតមាននោះ គឺថា ការបន្តឃុំឃាំងមិនមានមូលដ្ឋានច្បាប់ទេ។ ដើម្បីកុំឱ្យមានបញ្ហានេះ អង្គជំនុំជម្រះយល់ស្របគ្នាថា នៅក្នុងស្ថានភាពនេះត្រូវ ដោះលែងជនជាប់ចោទ។) សេចក្ដីសម្រេច កថាខណ្ឌ ៨០។

[34] សេចក្ដីសម្រេចដែលរងការជំទាស់ កថាខណ្ឌ ៨១។

[35] បណ្ដឹងសាទុក្ខ កថាខណ្ឌ២។

[36] សេចក្ដីសម្រេចដែលរងការជំទាស់ ទំព័រ៥០។

ស្ថិតក្នុងមន្ទីរឃុំឃាំង រហូតដល់ចេញសេចក្តីសម្រេច និង វិធាន ៦៣ និង វិធាន ៦៤ ដែលសម្រេចពីពេលវេលាសមរម្យដែលត្រូវដោះលែងជនជាប់ចោទពីមន្ទីរឃុំឃាំង[37]។ អង្គជំនុំជម្រះសាលាដំបូងក៏ខកខានផងដែរដោយមិនបានអនុវត្តឲ្យបានត្រឹមត្រូវនូវគោលការណ៍នានារបស់ច្បាប់ព្រហ្មទណ្ឌអន្តរជាតិ និងច្បាប់មនុស្សធម៌អន្តរជាតិ ដែលបង្ហាញថា "ការបន្តឃុំខ្លួន ឬដោះលែង ដែលត្រូវអនុវត្តដោយមានលក្ខខណ្ឌតឹងរ៉ឹង គឺជា *និយាម* ទៅហើយ នៅពេលដែលដំណើរការនីតិវិធីនៅក្នុងសំណុំរឿងព្រហ្មទណ្ឌអន្តរជាតិត្រូវផ្អាក ដោយសារតែការគ្មានសម្បទាគ្រប់គ្រាន់ ហើយនៅតែមានលទ្ធភាព (សូម្បីតែលទ្ធភាពតិចក្តី) ថាជនជាប់ចោទអាចមានសមត្ថភាពប្រសើរជាងមុន"[38]។ សហព្រះរាជអាជ្ញាក៏បានលើកឡើងផងដែរថា អង្គជំនុំជម្រះសាលាដំបូងបានរំលោភបំពានអំណាចឆន្ទានុសិទ្ធិរបស់ខ្លួន ដោយពុំអើពើពីមតិយោបល់អ្នកជំនាញវេជ្ជសាស្ត្ររបស់ខ្លួនដែលថា វិធានការកែលម្អអាចជួយឲ្យមានភាពប្រសើរឡើងនូវស្ថានភាពសុខភាពរបស់ជនជាប់ចោទបាន[39]។ ជាចុងក្រោយ អង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គច្បាប់ និង/ឬ រំលោភបំពានអំណាចឆន្ទានុសិទ្ធិរបស់ខ្លួន លើបញ្ហានៃផលវិបាកដែលកើតចេញពីការមិនមានមតិគាំទ្រភាគច្រើនលើសលប់ដើម្បីសម្រេចថាតើ ត្រូវដាក់លក្ខខណ្ឌលើការដោះលែងជនជាប់ចោទដែរ ឬយ៉ាងណា ។ សហព្រះរាជអាជ្ញាបានលើកឡើងជាទឡ្ហីករណ៍ថា "ដំណោះស្រាយ គឺថា ត្រូវរក្សា*ស្ថានភាពបច្ចុប្បន្ន* ហើយនៅក្នុងករណីនេះគឺត្រូវរក្សាការឃុំខ្លួន"[40]។

១១ នៅថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០១១ សហព្រះរាជអាជ្ញាបានដាក់សេចក្តីសន្និដ្ឋានបន្ថែមរបស់ខ្លួនដើម្បីឆ្លើយតបនឹងបញ្ហាដែលមិនបានលើកឡើងនៅក្នុងបណ្តឹងសាទុក្ខភ្លាមៗ[41]។ នៅក្នុងទឡ្ហីករណ៍ទីមួយនៃបណ្តឹងសាទុក្ខ សេចក្តីសន្និដ្ឋានបន្ថែមនោះបានលើកឡើងជាទឡ្ហីករណ៍ថា អំណាច "ក្នុងការត្រួតពិនិត្យស្ថានភាពសុខភាពជនជាប់ចោទជាប្រចាំ" ជាអំណាចផ្តាច់មុខរបស់អង្គជំនុំជម្រះសាលាដំបូង និងបានលើកជាទឡ្ហីករណ៍ថា វាពុំមែនជាការសមរម្យទេដែលសេចក្តីសម្រេចនេះបានផ្ទេរភារកិច្ចនេះមកឲ្យសហព្រះរាជអាជ្ញានោះ[42]។ នៅក្នុងទឡ្ហីករណ៍ទីពីរនៃបណ្តឹងសាទុក្ខរបស់ខ្លួន សហព្រះរាជអាជ្ញាលើកឡើងថា ការសន្និដ្ឋានថា បន្ទាប់ពីរកឃើញថាជនជាប់ចោទមិនមានសម្បទាក្នុងការចូលរួមសវនាការ ការអនុវត្តជាបទដ្ឋាននៅតុលាការព្រហ្មទណ្ឌអន្តរជាតិ និងតុលាការ*មិនអចិន្ត្រៃយ៍*ដទៃទៀត គឺត្រូវបង្គាប់ឲ្យផ្អាកកិច្ច

---

[37]បណ្តឹងសាទុក្ខ កថាខណ្ឌ៨-១១។

[38]បណ្តឹងសាទុក្ខ កថាខណ្ឌ១៣។

[39]បណ្តឹងសាទុក្ខ កថាខណ្ឌ១៥-១៦។

[40]បណ្តឹងសាទុក្ខបន្ទាន់ កថាខណ្ឌ១៨។

[41]សារណាបន្ថែម កថាខណ្ឌ៣។

[42]សារណាបន្ថែម កថាខណ្ឌ៤។

00759883



ដំណើរការនីតិវិធីជាបណ្តោះអាសន្ន ហើយមិនមែនជាការដោះលែងដោយគ្មានលក្ខខណ្ឌនោះទេ ទោះបីក្នុងករណីពាក់ព័ន្ធនឹងជម្ងឺដែលមានស្ថានភាពចុះដុនដាបជាលំដាប់ ឬក្នុងដំណាក់កាលចុងក្រោយក៏ដោយ[43]។ ហេតុនេះ អង្គជំនុំជម្រះសាលាដំបូង "បានបង្វែរទាំងស្រុងឲ្យងាកចេញពីយុត្តិសាស្ត្រ និងការអនុវត្តរបស់តុលាការអន្តរជាតិ និងតុលាការនានាដែលមានលក្ខណៈជាអន្តរជាតិផ្សេងៗទៀត" ដោយបង្គាប់ឲ្យដោះលែងជនជាប់ចោទដោយគ្មានលក្ខខណ្ឌ[44]។ សេចក្តីសន្និដ្ឋានបន្ថែមក៏បានអះអាងបន្ថែមទៀតថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គហេតុ និងអង្គច្បាប់ ដោយមិនបានពិចារណាទៅលើសក្ខីកម្មរបស់អ្នកជំនាញពាក់ព័ន្ធនឹងលទ្ធភាព ដែលអាចមានភាពប្រសើរឡើងវិញនូវស្ថានភាពសុខភាពរបស់ជនជាប់ចោទ[45]។ សហព្រះរាជអាជ្ញាបានចោទប្រកាន់ថា អង្គជំនុំជម្រះសាលាដំបូងខកខានមិនបានថ្លឹងថ្លែងឲ្យបានត្រឹមត្រូវដល់សិទ្ធិជំទាស់នានាដែលរងប៉ះពាល់ដោយការដោះលែងជនជាប់ចោទ ដូចជា "ផលប្រយោជន៍ខាងផ្លូវច្បាប់ និងសុវត្ថិភាពរបស់ជនរងគ្រោះ សាក្សី និងសហគមន៍" រួមទាំងផលប្រយោជន៍ខាងផ្លូវច្បាប់របស់សហគមន៍អន្តរជាតិ ក្នុងការចោទប្រកាន់ការរំលោភបំពានយ៉ាងធ្ងន់ធ្ងរចំពោះច្បាប់អន្តរជាតិ[46]។

១២ នៅក្នុងសារណាតប មេធាវីការពារក្តីបានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងបានសន្និដ្ឋានយ៉ាងត្រឹមត្រូវថា ពុំមានមូលដ្ឋានផ្លូវច្បាប់ណាមួយក្នុងការឃុំខ្លួនជនជាប់ចោទទៀតហើយ ដោយសារថា កិច្ចដំណើរការនីតិវិធីប្រឆាំងនឹងជនជាប់ចោទត្រូវបានផ្អាកដោយពុំមានរំពឹងថានឹងបន្តទៀតបានទេ[47]។ បើតាមការវិភាគល្អិតល្អន់ មេធាវីការពារក្តីបានលើកឡើងជាទឡ្ហីករណ៍ថា រឿងក្តីនានានៅតុលាការអន្តរជាតិដែលសហព្រះរាជអាជ្ញាបានលើកឡើងមិនបានបង្ហាញថា ការបន្តស្ថិតក្នុងមន្ទីរឃុំឃាំង ឬការឃុំខ្លួនគឺជាបទដ្ឋានទេ នៅពេលមានការសន្និដ្ឋានថាជនជាប់ចោទមិនមានសម្បទាគ្រប់គ្រាន់ក្នុងការចូលរួមសវនាការ ហើយថា ផ្ទុយទៅវិញ ស្ថានភាពនីមួយៗគួរតែត្រូវបានវាយតម្លៃទៅតាមករណីនីមួយៗ[48]។ អង្គជំនុំជម្រះសាលាដំបូងបានធ្វើការថ្លឹងថ្លែងយ៉ាងពេញលេញចំពោះសេចក្តីសន្និដ្ឋានរបស់អ្នកជំនាញ ទាក់ទិននឹងលទ្ធភាពដែលស្ថានភាពសុខភាពរបស់ជនជាប់ចោទអាចមានភាពប្រសើរឡើងវិញ ហើយអង្គជំនុំជម្រះនេះបានបង្គាប់យ៉ាងត្រឹមត្រូវឲ្យមានការដោះលែងជនជាប់ចោទដោយគ្មានលក្ខខណ្ឌ ពាក់ព័ន្ធនឹង"ស្ថាន

[43] សារណាបន្ថែម កថាខណ្ឌ៩។

[44] សារណាបន្ថែម កថាខណ្ឌ៩។

[45] សារណាបន្ថែម កថាខណ្ឌ២០។

[46] សារណាបន្ថែម កថាខណ្ឌ២៤-២៥។

[47] ចម្លើយតប កថាខណ្ឌ២១។

[48] ចម្លើយតប កថាខណ្ឌ២៤។

ភាពវិវត្តទៅមុខរបស់[ជនជាប់ចោទ] និងលទ្ធភាព[តិចតួច] ដែលថាជនជាប់ចោទអាចមានសម្បទាក្នុងការចូលរួមការជំនុំជម្រះក្តីវិញ”[49]។ ចុងក្រោយ សារណាតបបានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងមិនមានកំហុសលើអង្គច្បាប់ទេ ក្នុងការសម្រេចពីរបៀបដំណើរការនៅពេលមិនមានសម្លេងភាគច្រើនលើសលប់គាំទ្រ ដោយសារវិធីសាស្ត្ររបស់អង្គជំនុំជម្រះសាលាដំបូងស្របទៅនឹងវិធីសាស្ត្រដែលត្រូវបានយកមកប្រើប្រាស់ក្នុងស្ថានភាពស្រដៀងគ្នានេះដែរ ក្នុងសំណុំរឿង ០០១[50]។

## ៦. សំអាងហេតុ

### ៦.២ ការទទួលយកបណ្តឹងសាទុក្ខ

#### ៦.២.១.សារណារបស់ភាគី

១៣ សហព្រះរាជអាជ្ញាលើកឡើងថាបណ្តឹងសាទុក្ខភ្លាមៗរបស់ខ្លួន អាចទទួលយកបានតាមវិធាន១០៤(៤)(ក) និង (ខ)នៃវិធានផ្ទៃក្នុង។ ពាក់ព័ន្ធនឹងវិធាន១០៤(៤)(ក)នៃវិធានផ្ទៃក្នុង សហព្រះរាជអាជ្ញាលើកឡើងថា សេចក្តីសម្រេចដែលរងការជំទាស់ ពិតជាបញ្ចប់កិច្ចដំណើរការនីតិវិធីប្រឆាំងនឹងជនជាប់ចោទដោយហេតុថា “ដោយសារតែសហព្រះរាជអាជ្ញានឹងមិនមានលទ្ធភាពស្នើសុំឱ្យមានការបន្តកិច្ចដំណើរការនីតិវិធីឡើងវិញ”[51]។ ជាពិសេស សហព្រះរាជអាជ្ញាបានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងមិនមានមូលដ្ឋានផ្លូវច្បាប់ទេក្នុងការដែលផ្តល់ព័ត៌មានដល់សហព្រះរាជអាជ្ញាថា សហព្រះរាជអាជ្ញាត្រូវបង្កើតយន្តការត្រួតពិនិត្យស្ថានភាពសុខភាពរបស់ជនជាប់ចោទនោះ។ ដោយហេតុថាជនជាប់ចោទ ត្រូវបានដោះលែងដោយគ្មានលក្ខខណ្ឌ:

> មិនមានមូលដ្ឋានតម្រូវឱ្យជនជាប់ចោទទទួលការព្យាបាល ឬការធ្វើតេស្តសុខភាពបន្ថែមណាមួយទៀតទោះបីជាតាមសំណើរបស់សហព្រះរាជអាជ្ញាក៏ដោយ។ ហេតុដូច្នេះ សហព្រះរាជអាជ្ញា នឹងមិនមានលទ្ធភាពស្នើសុំឱ្យមានការបន្តកិច្ចដំណើរការនីតិវិធីឡើងវិញ ដោយហេតុថាសហព្រះរាជអាជ្ញានឹងមិនមានលទ្ធភាពបង្ហាញភស្តុតាងអំពីការផ្លាស់ប្តូរកាលៈទេសៈជាសត្យានុម័ត[52]។

---

[49] ចម្លើយតប កថាខណ្ឌ៣៨។

[50] ចម្លើយតប កថាខណ្ឌ៤៥។

[51] សារណាតប កថាខណ្ឌ ៣៨។

[52] សារណាតប កថាខណ្ឌ ៤៥។

SUPREME COURT CHAMBER CHAMBRE DE LA COUR SUPRÊME * E.C.C.C * C.E.T.C

១៤ នៅក្នុងសារណាតបរបស់ខ្លួន មេធាវីការពារក្តីមិនបានជំទាស់ថា បណ្តឹងសាទុក្ខភ្លាមៗនេះអាចទទួលយកបានតាមវិធាន១០៤(៤)(ខ)នៃវិធានផ្ទៃក្នុងនោះឡើយ។ ទោះបីជាយ៉ាងណាក៏ដោយ មេធាវីការពារក្តីបានលើកឡើងថា បណ្តឹងសាទុក្ខភ្លាមៗនេះ មិនអាចទទួលបានតាមវិធាន១០៤(៤)(ក)នោះឡើយ ដោយហេតុថា សេចក្តីសម្រេចដែលរងការជំទាស់មិនបានបញ្ចប់កិច្ចដំណើរការនីតិវិធីយ៉ាងពិតប្រាកដនោះឡើយ។ សេចក្តីសម្រេចដែលរងការជំទាស់ "បានបញ្ជាក់យ៉ាងច្បាស់ថា កិច្ចដំណើរការនីតិវិធីត្រូវបានផ្អាក ប៉ុន្តែមិនត្រូវបានបញ្ចប់ ឬបញ្ឈប់ ហើយមិនបានស្របតាមសារណារបស់មេធាវីការពារក្តីដែលថាជាការបញ្ឈប់កិច្ចដំណើរការនីតិវិធីនោះឡើយ"[53]។ មេធាវីការពារក្តីក៏បានលើកឡើងដែរថាកិច្ចដំណើរការនីតិវិធីមិនត្រូវបានបញ្ចប់នោះឡើយ ដោយហេតុថា សហព្រះរាជអាជ្ញាមានលទ្ធភាព តាមមុខងាររបស់ខ្លួនក្នុងការស្នើសុំអង្គជំនុំជម្រះសាលាដំបូង ឲ្យធ្វើការវាយតម្លៃឡើងវិញអំពីសុខភាពរបស់ជនជាប់ចោទ និងបន្តការជំនុំជម្រះឡើងវិញនៅពេលណាមួយក៏បាន[54]។

## ៦.២.២ ការពិចារណា

១៥ នីតិវិធីព្រហ្មទណ្ឌ ត្រូវបានរៀបចំឡើងដើម្បីទទួលបានការសម្រេចសេចក្តីលើបញ្ហានៃការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌតាមរយៈការចេញសាលក្រមលើអង្គសេចក្តី។ ការផ្អាកដែលមិនមានភាពច្បាស់លាស់អំពីការបន្តដំណើរការនីតិវិធី គឺពិតជាមានអានុភាពបញ្ចប់កិច្ចដំណើរការនីតិវិធីមិនឲ្យបន្តទៀត និងរារាំងដល់ការចេញសាលក្រមលើអង្គសេចក្តី។ ផលវិបាកនៃការអាក់ខានដែលបណ្តាលមកពីការផ្អាកកិច្ចដំណើរការនីតិវិធីនេះ មានកម្រិតធ្ងន់ធ្ងរគ្រប់គ្រាន់ក្នុងការសន្និដ្ឋានថា សេចក្តីសម្រេចផ្អាកកិច្ចដំណើរការនីតិវិធីនេះត្រូវតែជាកម្មវត្ថុនៃបណ្តឹងសាទុក្ខ។ ក្នុងកាលៈទេសៈពិសេសនេះ ការបកស្រាយសមហេតុផលតែមួយគត់នៃវិធាន១០៤(៤)(ក) នៃវិធានផ្ទៃក្នុង គឺថា "សេចក្តីសម្រេចដែលមានអានុភាពបញ្ចប់កិច្ចដំណើរការនីតិវិធី" រួមបញ្ចូលផងដែរនូវសេចក្តីសម្រេចផ្អាកកិច្ចដំណើរការនីតិវិធី នៅពេលដែលគ្មានក្តីសង្ឃឹមអំពីការបន្តនីតិវិធីទេ។ ការបកស្រាយនេះត្រូវបានបញ្ជាក់យ៉ាងពិតប្រាកដ តាមរយៈការជ្រើសរើសពាក្យពេចន៍ជាក់លាក់នៅក្នុងវិធាន១០៤(៤)(ក) នៃវិធានផ្ទៃក្នុង ("*អានុភាពបញ្ចប់*កិច្ចដំណើរការនីតិវិធី មានភាពខុសគ្នាទៅនឹងសេចក្តីសម្រេចដែល *បញ្ចប់*កិច្ចដំណើរការនីតិវិធី") ក៏ដូចជានៅតុលាការព្រហ្មទណ្ឌ

[53] សារណាបន្ថែម កថាខណ្ឌ ៤។

[54] សារណាតប កថាខណ្ឌ ១៧។

00759886



ដែលមានលក្ខណៈជាអន្តរជាតិ ដែលអនុញ្ញាតឲ្យមានបណ្តឹងសាទុក្ខបន្ទាន់បង្ខំប្រឆាំងនឹងការផ្អាកកិច្ចដំណើរការនីតិវិធី[55]។

## ៦.៣ អង្គសេចក្តីនៃបណ្តឹងសាទុក្ខផ្សេងៗ

### ៦.៣.១ផលវិបាកផ្នែកនីតិវិធីដែលបណ្តាលមកពីការផ្អាកកិច្ចដំណើរការនីតិវិធី

១៦ សំអាងហេតុដែលអង្គជំនុំជម្រះសាលាដំបូងបានលើកឡើងនៅក្នុងសេចក្តីសម្រេចរបស់ខ្លួន ដើម្បីផ្អាកកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌប្រឆាំងនឹងជនជាប់ចោទ គឺជាសំអាងហេតុដែលថា ជនជាប់ចោទមិនមានសម្បទាក្នុងការចូលរួមសវនាការ[56]។ អង្គជំនុំជម្រះសាលាដំបូងមិនបានផ្តល់មូលដ្ឋានគតិយុត្តចំពោះការសម្រេចផ្អាកកិច្ចដំណើរការនីតិវិធីនោះទេ។ អង្គជំនុំជម្រះសាលាដំបូង ក៏មិនបានកំណត់អំពីផលវិបាកផ្នែកនីតិវិធីដែលបណ្តាលមកពីការផ្អាកកិច្ចដំណើរការនីតិវិធីនោះដែរ ក្រៅតែពីការផ្តល់សំអាងហេតុដែលថា តាមរយៈផលប៉ះពាល់រួមនៃការមិនមានសម្បទាក្នុងពេលបច្ចុប្បន្ន ការបំបែកបទចោទប្រឆាំងនឹងជនជាប់ចោទ និងការផ្អាកកិច្ចដំណើរការនីតិវិធីលើជនជាប់ចោទនេះក្នុងសំណុំរឿង០០២ អង្គជំនុំជម្រះសាលាដំបូងពុំមានមូលដ្ឋានគតិយុត្តណាមួយដើម្បីបន្តឃុំខ្លួនជនជាប់ចោទឡើយ[57]។ អង្គជំនុំជម្រះសាលាដំបូង ជាឯកច្ឆន្ទបានសង្កត់ធ្ងន់ផងដែរថា ការផ្អាកកិច្ចដំណើរការនីតិវិធី មិនតម្រូវឲ្យបញ្ចប់កិច្ចដំណើរការនីតិវិធីប្រឆាំងនឹងជនជាប់ចោទនោះទេ[58]។ ហេតុដូច្នេះ អង្គជំនុំជម្រះតុលាការកំពូល ត្រូវចាប់ផ្តើមពិនិត្យឡើងវិញលើខ្លឹមសារបណ្តឹងសាទុក្ខនេះ ដោយធ្វើការពិចារណាអំពីលក្ខណៈ និងផលវិបាកគតិយុត្តដែលបណ្តាលមកពីការផ្អាកកិច្ចដំណើរការនីតិវិធី ដែលសម្រេចដោយអង្គជំនុំជម្រះសាលាដំបូង។

---

[55]ឧទាហរណ៍...*រដ្ឋអាជ្ញា ទល់នឹង Thomas Lubanga Dyilo*, ICC-01/04-01/06-2582, "សាលក្រមស្តីពីបណ្តឹងសាទុក្ខរបស់រដ្ឋអាជ្ញាប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង I ថ្ងៃទី៨ ខែកក្កដា ឆ្នាំ២០១០ ឈ្មោះថា 'សេចក្តីសម្រេចស្តីពីសំណើបន្ទាន់របស់រដ្ឋអាជ្ញាសុំផ្លាស់ប្តូរកាលបរិច្ឆេទដើម្បីបង្ហាញអំពីអត្តសញ្ញាណនៃអន្តរការី ១៤៣ ឬផ្អាកកិច្ចដំណើរការនីតិវិធីរង់ចាំងការពិភាក្សាបន្ថែមជាមួយ VWU'" អង្គជំនុំជម្រះតុលាការកំពូល ថ្ងៃទី៨ ខែតុលា ឆ្នាំ២០១០ កថាខណ្ឌ ៥៥-៦២។

[56]សេចក្តីសម្រេចដែលរងការជំទាស់ កថាខណ្ឌ ៨០ ("អង្គជំនុំជម្រះសាលាដំបូង បានយល់ស្របជាឯកច្ឆន្ទថា អៀង ធីរិទ្ធ មិនមានសម្បទាចូលរួមសវនាការ ហើយជាផលវិបាក ផ្អាកដំណើរការនីតិវិធី")។

[57]សេចក្តីសម្រេចដែលរងការជំទាស់ កថាខណ្ឌ ៦១។

[58]សេចក្តីសម្រេចដែលរងការជំទាស់ កថាខណ្ឌ៦៤ ("ជាថ្មីម្តងទៀត យើង ចៅក្រមជាតិ យល់ស្របទៅនឹង[illegible] និងកត់សម្គាល់ថា ដោយយោងតាមសហការីចៅក្រមអន្តរជាតិ កិច្ចដំណើរការនីតិវិធី ត្រូវបានផ្អាក ប៉ុន្តែមិនត្រូវបាន[illegible]ទេ")។

១៧ កិច្ចព្រមព្រៀង អ.វ.ត.ក ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក និងវិធានផ្ទៃក្នុង មិនបានចែងអំពី "ការផ្អាកកិច្ចដំណើរការនីតិវិធី" នៅចំពោះមុខ អ.វ.ត.ក នោះទេ។ ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ចែងអំពីអំណាច "បង្អង់" ឬ "ផ្អាក" កិច្ចដំណើរការនីតិវិធីនៅក្នុងកាលៈទេសៈមួយចំនួនដែលជាឧបសគ្គដល់ការបន្តកិច្ចដំណើរការនីតិវិធី ដូចជា ភាពចាំបាច់ដើម្បីសម្រេចអំពីបញ្ហាបន្ទាន់បង្ខំដែលទាក់ទងនឹងការរកឃើញធាតុផ្សំសត្យានុម័តនៃបទល្មើសដែលស្ថិតនៅក្រោមយុត្តាធិការផ្តាច់មុខរបស់តុលាការមួយផ្សេងទៀត[59] និងនៅពេលជនជាប់ចោទមិនចូលបង្ហាញខ្លួននៅចំពោះមុខតុលាការ[60]។ ទោះបីជាយ៉ាងណាក៏ដោយ ច្បាប់កម្ពុជា មិនបានកំណត់ពីផលប៉ះពាល់នៃការផ្អាកកិច្ចដំណើរការនីតិវិធី ទៅលើការអនុវត្តសិទ្ធិ កាតព្វកិច្ច និងសមត្ថកិច្ច ក្នុងអំឡុងពេលផ្អាកកិច្ចដំណើរការនីតិវិធីនោះឡើយ។ ដោយមិនមានបទប្បញ្ញត្តិចែងជាក់លាក់នៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា មូលដ្ឋាន និងអានុភាពនៃការផ្អាកដំណើរការនីតិវិធី អាចត្រូវបានបកស្រាយដោយប្រុងប្រយ័ត្នតាមរយៈសទិសភាព និងតាមការណែនាំពីការអនុវត្តក្នុងកម្រិតជាតិ[61] និង អន្តរជាតិ[62]តាមមាត្រា ១២ ១៣(១) នៃកិច្ចព្រមព្រៀង អ.វ.ត.ក និងមាត្រា ៣៣ (ថ្មី) នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក។

---

[59]ក្រមនីតិវិធីព្រហ្មទណ្ឌ មាត្រា ៣៤៣ ៣៤៥។ ពាក្យពេចន៍ដើមជាភាសាខ្មែរតែមួយ ត្រូវបានប្រើប្រាស់ក្នុងបទប្បញ្ញត្តិពីរ ហើយមានន័យដូចគ្នាទៅនឹងភាសាអង់គ្លេសថា "suspend" ឬ "stay"។ "suspension" ឬ "stay" ដែលជាភាសាខ្មែរនៅក្នុងក្រមនីតិវិធីខុសប្លែកពីពាក្យថា "adjournment" ដែលពាក្យនេះ មានន័យថា ការអាក់ខានដែលមានរយៈពេលខ្លីនៃសកម្មភាពក្នុងខណៈដែលកិច្ច ដំណើរការនីតិវិធី កំពុងបន្ត។(មាត្រា ៣៤០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)។

[60]ក្រមនីតិវិធី មាត្រា ៣១០។

[61]ឧទាហរណ៍ មាត្រា ៣០៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ កូរ៉េខាងត្បូង(កំណត់អំពីការផ្អាកកិច្ចដំណើរការនីតិវិធី ប្រសិនបើជនជាប់ចោទត្រូវបានរកឃើញថា មិនមានសម្បទាចូលរួមសវនាការ។ កិច្ចដំណើរការនីតិវិធី អាចបន្តឡើងវិញបានបន្ទាប់ពីមានការចាត់តាំងអ្នកដំណាង ផ្នែកច្បាប់ដោយស្របតាមមាត្រា ២៦ ៣៧៤(២) និង៣៧៥(១) នៃក្រមនីតិវិធីព្រហ្មទណ្ឌសិរិលង្កា (ចែងថា ប្រសិនបើជនជាប់ចោទ មិនមានសម្បទាសមស្របទេនោះ និងជាផលវិបាក មិនអាចការពារក្តីដោយខ្លួនឯងបាន តុលាការត្រូវផ្អាកកិច្ចដំណើរការនីតិវិធី។ មាត្រា ៧០ ៧១ ៧២ នៃក្រមនីតិវិធីព្រហ្មទណ្ឌអ៊ីតាលី (ចែងថា ការផ្អាកកិច្ចដំណើរការនីតិវិធី នៅពេលដែលជនជាប់ចោទមិនមានសម្បទាចូលរួមសវនាការ។ ការវាយតម្លៃឡើងវិញចាំបាច់លើលក្ខខណ្ឌរបស់ជនជាប់ចោទ ត្រូវតែធ្វើឡើងដោយអាជ្ញាធរមានសមត្ថកិច្ចរបស់តុលាការ យ៉ាងតិចត្រឹមរយៈពេល០៦ខែ)។ មាត្រា២២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ប៉ូឡូញ(ចែងថា នៅពេលដែលជនជាប់ចោទមិនអាចចូលរួមសវនាការបានក្នុងដំណើរការនីតិវិធីនោះ ដោយសារតែបញ្ហាស្មារតី ឬជំងឺធ្ងន់ធ្ងរផ្សេងទៀតនោះ កិច្ចដំណើរការនីតិវិធីត្រូវតែផ្អាកសម្រាប់រយៈពេលនៃឧបសគ្គនេះ)។

[62]មើល រដ្ឋអាជ្ញា ទល់នឹង Lubangar, ICC-01/04-01/06-1486, "សាលក្រមស្តីពីបណ្តឹងសាទុក្ខរបស់រដ្ឋអាជ្ញាប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ហៅថា "សេចក្តីសម្រេចស្តីពីផលវិបាកនៃការមិនបង្ហាញវត្ថុតាងដោះបន្ទុកដោយអនុលោមតាមមាត្រា៥៤(៣)(ង) នៃកិច្ចព្រមព្រៀង និងការអនុវត្តក្នុងការផ្អាកការចោទប្រកាន់ជនជាប់ចោទ ជាមួយនឹងបញ្ហាមួយចំនួនផ្សេងទៀត ដែលបានលើកឡើងនៅក្នុងកិច្ចប្រជុំស្តីពីឋានៈ នៅថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៨"" អង្គជំនុំជម្រះតុលាការកំពូល ថ្ងៃទី២១ ខែតុលា ឆ្នាំ

១៨ “ការផ្អាក” សំដៅដល់ “ការពន្យា ឬការព្យួរកិច្ចដំណើរការនីតិវិធី សាលក្រម ឬដែលមានលក្ខណៈប្រហាក់ប្រហែល” និងសំដៅដល់ “ការបង្គាប់ឱ្យបង្អង់ទាំងស្រុង ឬផ្នែកណាមួយនៃកិច្ចដំណើរការនីតិវិធីតុលាការ ឬសាលក្រមដែលចេញមកពីកិច្ចដំណើរការនីតិវិធីនោះ”[63]។ នៅពេលដែលមានការអនុញ្ញាតឱ្យផ្អាកកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌ ការផ្អាកនេះមានតួនាទីដោះស្រាយឧបសគ្គដែលកើតមានយូរអង្វែងចំពោះការបន្តកិច្ចដំណើរការនីតិវិធី។ ជាចុងក្រោយ ទោះបីជាឧបសគ្គមិនទាន់បានដោះស្រាយក៏ដោយក៏ស្ថានភាពនៃការផ្អាកនេះ ត្រូវបានផុតរលត់ ដោយសារការបញ្ចប់នៃដំណើរការនីតិវិធីបន្ទាប់ពីមរណភាពរបស់ជនជាប់ចោទ ឬផុតអាជ្ញាយុកាលនៅពេលដែលប្រពន្ធ័ច្បាប់អនុញ្ញាតដូច្នេះ។ ដោយមិនគិតដល់មូលដ្ឋានក្នុងការបង្គាប់ឱ្យមានការផ្អាកដោយផ្អែកតាមកាលៈទេសៈជាក់ស្តែងមួយចំនួន ស្ថានភាពដែលជាលទ្ធផលនៃការផ្អាកនេះ ពិតជាធ្វើឱ្យប៉ះពាល់ដល់ចរិត និងគោលបំណងនៃកិច្ចដំណើរការនីតិវិធី។ លក្ខណៈពិសេសមួយដែលជាផលវិបាកបណ្តាលមកពីការផ្អាកកិច្ចដំណើរការនីតិវិធីនេះ គឺថា ទោះបីជាកិច្ចដំណើរការនីតិវិធី ត្រូវបានផ្អាកក៏ដោយ ក៏ការផ្អាកនេះមិនបានធ្វើឱ្យរាំងស្ទះដល់កិច្ចដំណើរការនីតិវិធីដែលមានគោលបំណងដោះស្រាយបញ្ហាដែលជាឧបសគ្គ នោះដែរ[64]។ ការបំពេញកិច្ចដំណើរការនីតិវិធីនេះ គឺជាកាតព្វកិច្ចរបស់អាជ្ញាធរដែលមានយុត្តាធិការលើរឿងក្តីនេះ។ កាតព្វកិច្ចនេះផ្អែកលើតួនាទីក្នុងការចោទប្រកាន់ ការសន្មតទុកជាមុនថាគ្មានទោស ភាពយុត្តិធម៌ ទាក់ទងនឹងសិទ្ធិក្នុងការទទួលបានការជំនុំជម្រះក្តីនៅក្នុងពេលវេលាសមស្រប និងការសន្សំសំចៃការចំណាយលើកិច្ចដំណើរការនីតិវិធី។

១៩ ទាក់ទងនឹងកាតព្វកិច្ចធ្វើការចោទប្រកាន់ នៅក្នុងតុលាការព្រហ្មទណ្ឌអន្តរជាតិដោយផ្អែកទៅលើភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្មអន្តរជាតិ និងដោយសារធនធានមានកម្រិត ការចោទប្រកាន់មិនតម្រូវឱ្យធ្វើប្រឆាំងនឹងជនសង្ស័យគ្រប់រូបពីបទឧក្រិដ្ឋដែលស្ថិតក្នុងដែនយុត្តាធិការរបស់តុលាការនោះទេ។ ហេតុដូច្នេះ ការចោទប្រកាន់ អាចត្រូវការអនុវត្តនូវកម្រិតភស្តុតាងមួយខ្ពស់ជាងកម្រិតភស្តុតាងនៅក្នុងនីតិវិធីក្នុងកម្រិត

---

២០០៨ កថាខណ្ឌ ៨២ ជើងទំព័រ ៦-៨ (បានផ្តល់នូវឧទាហរណ៍ពីតុលាការ ICTY និង ICTR ដែល “ការផ្អាកកិច្ចដំណើរការនីតិវិធីនៃស្ថានភាពមិនអចិន្ត្រៃយ៍ ត្រូវបានធ្វើឡើង”)។

[63]វចនានុក្រមច្បាប់ Black Law លើកទី៩ ឆ្នាំ២០០៩ ទំព័រ១៥៤៨ ពាក្យ “stay”។

[64]មើល ឧទាហរណ៍ មាត្រា៣៤៥ នៃក្រមនីតិវិធី (“កាលណាបញ្ហាបន្ទាន់បង្គំត្រូវបានលើកឡើង និងត្រូវបានទទួលយល់ព្រមដោយតុលាការនោះ តុលាការនេះ ត្រូវបង្អង់មិនទាន់សម្រេច ហើយកំណត់រយៈពេលឱ្យភាគីពាក់ព័ន្ធប្តឹងទៅតុលាការមានសមត្ថកិច្ច”)។ មើល [illegible] មាត្រា៣១០ នៃក្រមនីតិវិធី (តម្រូវឱ្យតុលាការចេញដីកាបង្គាប់ឱ្យនាំខ្លួនជនជាប់ចោទ)។

ជាតិ[65]។ ទោះបីយ៉ាងណាក៏ដោយ នៅពេលបុគ្គលមួយរូបត្រូវបានចោទប្រកាន់ តុលាការព្រហ្មទណ្ឌអន្តរជាតិ ត្រូវខិតខំប្រឹងប្រែងឱ្យអស់ពីសមត្ថភាពដើម្បីធានាថា ត្រូវធ្វើឱ្យអស់ពីលទ្ធភាពដើម្បីកាត់សេចក្តីលើជនជាប់ចោទ ទោះបីជានៅពេលដែលជនជាប់ចោទមានបញ្ហាសុខភាពធ្ងន់ធ្ងរក៏ដោយ។ ជាឧទាហរណ៍ នៅក្នុងរឿងក្តី *Djukić* អ្នកជំនាញវេជ្ជសាស្ត្រ បានបង្ហាញរបាយការណ៍ថា ជនជាប់ចោទស្ថិតក្នុងដំណាក់កាលចុងក្រោយ នៃជំងឺដែលមិនអាចព្យាបាលបាន[66]។ តុលាការ ICTY បានបង្គាប់ឱ្យដោះលែងជនជាប់ចោទជាបណ្តោះអាសន្ន "ដោយសារមូលហេតុមនុស្សធម៌តែប៉ុណ្ណោះ" ដោយបានធ្វើការបដិសេធសំណើរបស់មេធាវីការពារក្តី និងអយ្យការ ដែលសុំដកដីកាបញ្ជូនរឿងទៅជំនុំជម្រះ[67]។ ដីកាបញ្ជូនរឿងទៅជំនុំជម្រះ មិនត្រូវបានបញ្ចប់ឡើយ ទោះបីជាស្ថានភាពជំងឺរបស់ជនជាប់ មានលក្ខណៈធ្ងន់ធ្ងរក៏ដោយ ដូចជាជំងឺស្លាប់មួយចំហៀងខ្លួន[68]ឬស្ថានភាពស្មារតីដែលមិនឃើញថា មានលក្ខណៈប្រសើរឡើងអស់រយៈពេលជាច្រើនឆ្នាំ[69]។ តុលាការ ICTY ធ្វើការបញ្ចប់កិច្ចដំណើរការនីតិវិធីលើជនជាប់ចោទតែក្រោយពេលដែលជនជាប់ចោទស្លាប់ប៉ុណ្ណោះ[70]។

---

[65] *សហព្រះរាជអាជ្ញា ទល់នឹង កាំង ហ្គេក អ៊ាវ ហៅ ឌុច* សំណុំរឿងលេខ ០០១/១៨-០៧-២០០៧ អ.វ.ត.ក-អ.ជ.ស.ដ សាលក្រមសាលាដំបូង កថាខណ្ឌ២៤ ជើងទំព័រ៣៣។

[66] *រដ្ឋអាជ្ញា ទល់នឹង Djordje Djukić* IT-96-20-T , "សេចក្តីសម្រេចបដិសេធសំណើសុំដកដីកាបញ្ជូនរឿងទៅជំនុំជម្រះ និងដីកាបង្គាប់ឱ្យដោះលែងបណ្តោះអាសន្ន"។ អង្គជំនុំជម្រះសាលាដំបូង ថ្ងៃទី២៤ ខែមេសា ឆ្នាំ១៩៩៦ ទំព័រ ៣-៤។

**ដោយពិចារណាថា** ឧត្តមសេនីយ៍ Djukic មានជំងឺដែលមិនអាចព្យាបាលបាន ដែលតាមមតិយោបល់របស់អ្នកជំនាញវេជ្ជសាស្ត្រ គឺស្ថិតក្នុងដំណាក់កាលចុងក្រោយ...**ដោយពិចារណាឃើញថា** ភាពធ្ងន់ធ្ងរនៃស្ថានភាពវេជ្ជសាស្ត្របច្ចុប្បន្ន នៃឧត្តមសេនីយ៍Djukic មិនសមស្របទៅនឹងទម្រង់នៃការឃុំខ្លួនណាមួយឡើយ ហើយថា ការព្យាបាលបណ្តោះអាសន្ន ដែលតម្រូវនេះសម្រាប់ស្ថានភាពរបស់ជនជាប់ចោទ ឬនឹងតម្រូវ បង្ហាញថា បរិយាកាសផ្សេងៗទៀតមានលក្ខណៈត្រឹមត្រូវ។

[67] *រដ្ឋអាជ្ញា ទល់នឹង Djordje Djukić* IT-96-20-T , "សេចក្តីសម្រេចបដិសេធសំណើសុំដកដីកាបញ្ជូនរឿងទៅជំនុំជម្រះ និងដីកាបង្គាប់ឱ្យដោះលែងបណ្តោះអាសន្ន"។ អង្គជំនុំជម្រះសាលាដំបូង ថ្ងៃទី២៤ ខែមេសា ឆ្នាំ១៩៩៦ ទំព័រ ៣-៥។

[68] *រដ្ឋអាជ្ញា ទល់នឹង Milan Simic IT-95-9/2* "ដីកាបង្គាប់របស់ប្រធានលើសំណើសុំដោះលែងមុនកំណត់ជនជាប់ចោទ Milan Simic", ប្រធាន ថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៣ ទំព័រ ២ ("Milan Simic មានជំងឺស្លាប់មួយចំហៀងខ្លួន ដោយស្ថិតកៅអីរុញ ហើយត្រូវការការគាំពារជារៀងរាល់ថ្ងៃ")។

[69] *រឿងក្តី រដ្ឋអាជ្ញាតទល់នឹងKovačević,* IT-01-42/2-1, "សំណៅជាសាធារណៈនៃសេចក្តីសម្រេចស្តីពីសម្បទារបស់ជនជាប់ចោទក្នុងការផ្តល់ចម្លើយនិងចូលរួមសវនាការ" អង្គជំនុំជម្រះសាលាដំបូង I, ថ្ងៃទី១២ ខែមេសា ឆ្នាំ២០០៦។ រឿងក្តី *Vladimir Kovacevic* "មេធាវីការពារក្តីរំលឹកថា ម្ចាស់បណ្តឹងសាទុក្ខ ត្រូវបានធ្វើរោគវិនិច្ឆ័យថាមានវិកលចរិក ហើយយល់ឃើញថា ជនជាប់ចោទមិនមានសម្បទាចូលសវនាការ")។

[70] *រឿងក្តីរដ្ឋអាជ្ញាតទល់នឹងDjordje Djukić,*IT-96-20-T "ដីកាសម្រេចបញ្ចប់កិច្ចដំណើរការនីតិវិធីលើបណ្តឹងសាទុក្ខ" អង្គជំនុំជម្រះ តុលាការកំពូល ថ្ងៃទី២៩ខែឧសភាឆ្នាំ១៩៩៦។ *រដ្ឋអាជ្ញាតទល់នឹងMomir Talic,* IT-99-36/1-T,"ដីកាសម្រេចបញ្ចប់កិច្ចដំណើរការនីតិវិធីប្រឆាំងនឹង *Momir Talic*" អង្គជំនុំជម្រះសាលាដំបូង II ថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០០៣។

២០ បញ្ហាដែលពាក់ព័ន្ធមួយ គឺថាតើវិធានការនៃការបង្ខំ អាចយកមកអនុវត្តទាក់ទងនឹងការមិនមានសម្បទាចំពោះជនជាប់ចោទដែលមានស្ថានភាពសុខភាពធ្ងន់ធ្ងរ ក្នុងអំឡុងពេលផ្អាកកិច្ចដំណើរការនីតិវិធីបាន ដែរឬយ៉ាងណា។ នៅក្នុងយុត្តិសាស្ត្ររបស់តុលាការ ICTY បង្ហាញថា វិធានការក្នុងការធានាឲ្យមានវត្តមានរបស់ជនជាបចោទ នៅចំពោះមុខតុលាការនោះ ត្រូវបានយកមកអនុវត្ត ដោយមិនគិតពីបញ្ហាសុខភាពរបស់ជនជាប់ចោទឡើយ។ ជាឧទាហរណ៍ នៅក្នុង *រឿងក្តី Radoslav Brdanin និង Momir Talic,* Talic “មានជំងឺដំបៅមហារីកកម្រិតធ្ងន់ធ្ងរដែលមិនអាចព្យាបាលបាន និងមិនអាចវះកាត់បាន [...] ដែលត្រូវបានសន្មតថាស្ថិតនៅដំណាក់កាល III-B ដោយមានការប៉ាន់ស្មានថាអាចមានជីវិតរស់ក្នុងរយៈពេលខ្លីប៉ុណ្ណោះ”[71]។ អង្គជំនុំជម្រះសាលាដំបូង II បានបង្គាប់ឲ្យដោះលែង Talic ជាបណ្តោះអាសន្ន ដោយផ្អែកលើ “ស្ថានភាពធ្ងន់ធ្ងរបំផុត” និង មូលហេតុមនុស្សធម៌ ដូចជាបញ្ហាសុខភាព។ “ការដោះលែង” ជនជាប់ចោទរូបនេះ ត្រូវបានជះឥទ្ធិពលផ្ទាល់ទៅលើការឃុំខ្លួនមន្ត្រី Yugoslav និងក្រោយមក ទៅលើទម្រង់នៃ “ការឃុំខ្លួនក្នុងផ្ទះ”[72]។ ជាក់ច្បាស់ណាស់ ពាក្យពេចន៍ “ការដោះលែង” នៅក្នុងសេចក្តីសម្រេចរបស់តុលាការ ICTY មិនមានន័យថាដោះលែងជនជាប់ចោទឲ្យមានសេរីភាពនោះទេ ប៉ុន្តែគ្រាន់តែជាពាក្យបច្ចេកទេស ដែលចង្អុលប្រាប់ឲ្យបញ្ឈប់ការឃុំខ្លួន ក្រោមយុត្តាធិការរបស់តុលាការ ICTY និងបញ្ឈប់គ្រប់គ្រងដោយប្រគល់ជនជាប់ចោទ ឲ្យទៅអាជ្ញាធរ Yugoslav ដែលផ្តល់ការធានាការគ្រប់គ្រងនោះ។ អង្គជំនុំជម្រះបានរៀបរាប់ប្រភេទនៃវិធានការដូចខាងក្រោម៖

> អង្គជំនុំជម្រះជឿជាក់ថា នៅក្នុងស្ថានភាពបែបនោះ ការដាក់លក្ខខណ្ឌដើម្បីគ្រប់គ្រងលើនិវេសនដ្ឋាន នាពេលបច្ចុប្បន្ននេះ គឺជាវិធានការគ្រប់គ្រាន់។ អង្គជំនុំជម្រះសាលាដំបូងនេះ ជឿជាក់ថា វិធានការបែបនេះមានចេតនា និងគោលបំណងដូចគ្នានឹងចំណាត់ថ្នាក់នៃការឃុំខ្លួននៅក្នុងផ្ទះ យ៉ាងហោចណាស់ពាក់ព័ន្ធនឹងការដើរហើរដោយសេរី និង [...] អាចនៅតែត្រូវបានចាត់ទុកថាជា *ទម្រង់នៃការឃុំខ្លួន*[73]។

[71]រឿងក្តី *រដ្ឋអាជ្ញា តទល់នឹងRadoslav Brdanin and Momir Talic*IT-99-36-T, “សេចក្តីសម្រេចលើសំណើសុំដោះលែងជនជាប់ចោទMomir Talicជាបណ្តោះអាសន្ន,អង្គជំនុំជម្រះសាលាដំបូង II ថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០០២ កថាខណ្ឌ ៣៥។

[72]រឿងក្តី *រដ្ឋអាជ្ញា តទល់នឹងRadoslav Brdanin and Momir Talic* សេចក្តីសម្រេចលើសំណើសុំដោះលែងជនជាប់ចោទMomir Talic ជាបណ្តោះអាសន្ន, IT-99-36-T,អង្គជំនុំជម្រះ សាលាដំបូង II ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០០២ កថាខណ្ឌ ៣៥។

[73]រឿងក្តី *រដ្ឋអាជ្ញា តទល់នឹងRadoslav Brdanin and Momir Talic*IT-99-36-T“សេចក្តីសម្រេចលើសំណើសុំដោះលែងជនជាប់ចោទ Momir Talic ជាបណ្តោះអាសន្ន”, អង្គជំនុំជម្រះសាលាដំបូងII ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០០២ កថាខណ្ឌ ៣៥។ នៅថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០០៣ សំណុំរឿងប្រឆាំងនឹង Talicត្រូវបានបញ្ចប់ដោយសារបញ្ហាសុខភាព នៅថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០០៣។

២១ នៅក្នុង *រឿងក្តី Stanisić និង Simatović* អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY បានទទួលយកសំណើសុំរបស់មេធាវីការពារក្តីជនជាប់ចោទ Jovica Stanisić សុំឲ្យពន្យាពេលការជំនុំជម្រះរយៈពេលអប្បបរមាបីខែ និងសុំធ្វើការវាយតម្លៃឡើងវិញលើស្ថានភាពសុខភាពរបស់ជនជាប់ចោទ មុនពេលកំណត់ពេលវេលាចាប់ផ្តើមសវនាការ[74]។ ក្រោយមក អង្គជំនុំជម្រះសាលាដំបូងបានដោះលែងជនជាប់ចោទជាបណ្តោះអាសន្នដោយមានលក្ខខណ្ឌ ដោយក្នុងចំណោមលក្ខខណ្ឌនោះ ជនជាប់ចោទត្រូវនាំទៅកាន់មន្ទីរពេទ្យនៅទីក្រុង Belgrade ត្រូវបានវាយតម្លៃ ហើយក្នុងករណីចាំបាច់ អនុញ្ញាតឲ្យមានការព្យាបាលដោយស្ថិតក្រោមលក្ខខណ្ឌ ដែលអាចរួមបញ្ចូលទាំង "ការអនុញ្ញាតដាក់នៅកន្លែងសុវត្ថិភាព ឬកន្លែងបិទជិតនៅក្នុងមន្ទីរពេទ្យនោះ"។ ជាជម្រើស ក្នុងករណីដែល ជនជាប់ចោទ *Stanisić* មិនត្រូវបានអនុញ្ញាតឲ្យទៅកាន់មន្ទីរពេទ្យទេនោះ ជនជាប់ចោទ ត្រូវរាយការណ៍ទៅប៉ុស្តិ៍នគរបាលជារៀងរាល់ថ្ងៃ[75]។

២២ *រឿងក្តី Vladimir Kovacevic* អង្គជំនុំជម្រះសាលាដំបូង I បានពន្យាកិច្ចដំណើរការនីតិវិធី រយៈពេលប្រាំមួយខែ និងបានបង្គាប់ឲ្យដោះលែងជាបណ្តោះអាសន្ន ដោយដាក់លក្ខខណ្ឌមួយចំនួន រួមមាន៖

(១) ជនជាប់ចោទ ត្រូវដាក់ឲ្យព្យាបាលនៅមណ្ឌលសុខភាពផ្នែកស្មារតីនៅក្នុងសាធារណរដ្ឋស៊ែប (Republic of Serbia) និងម៉ុងតេនេក្រូ (Montenegro) ដែលកំណត់ដោយរដ្ឋាភិបាល។

(២) ជនជាប់ចោទ មិនត្រូវចាកចេញពីបរិវេណនៃមណ្ឌលសុខភាពផ្នែកស្មារតី លុះត្រាតែការចាកចេញនេះគឺជាផ្នែកនៃការព្យាបាលគាត់ និងក្រោយពីទទួលបានការយល់ព្រមពីអង្គជំនុំជម្រះ[76]។

[74] រឿងក្តី *រដ្ឋអាជ្ញា តទល់នឹងJovica Stanisic and Franko Simatovic*, IT-03-69-AR73.2"សេចក្តីសម្រេចស្តីពីបណ្តឹងសាទុក្ខរបស់មេធាវីការពារក្តីប្រឆាំងនឹងសេចក្តីសម្រេចស្តីពីកិច្ចដំណើរការនីតិវិធីនៅពេលអនាគត"អង្គជំនុំជម្រះតុលាការកំពូល ថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០០៨ កថាខណ្ឌ ២២។

[75] រឿងក្តី *រដ្ឋអាជ្ញា តទល់នឹងJovica Stanisic and Franko Simatovic*, IT-03-69-PT"សេចក្តីសម្រេចស្តីពីការដោះលែងជាបណ្តោះអាសន្ន" អង្គជំនុំជម្រះសាលាដំបូង III ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០០៨ កថាខណ្ឌ ៦៨(១)(ឃ) (xiii)-(xiv) ដែលត្រូវបាន តម្កល់នៅដំណាក់កាលបណ្តឹងសាទុក្ខ IT -03-69-AR6S.4 "សេចក្តីសម្រេចលើបណ្តឹងសាទុក្ខស្តីពីការចោទប្រកាន់នៃសេចក្តីសេចក្តីសម្រេចស្តីពីការដោះលែងជាបណ្តោះអាសន្ន និងសំណើសុំបង្ហាញភស្តុតាងបន្ថែម ដោយអនុលោមតាមវិធាន ១១៥" អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០០៨។

[76] រឿងក្តី *Vladimir Kovačević*, IT-01-42/2-I, T "សេចក្តីសម្រេចស្តីពីការដោះលែងជាបណ្តោះអាសន្ន" អង្គជំនុំជម្រះសាលាដំបូងI ចុះថ្ងៃទី២ ខែមិថុនា ឆ្នាំ២០០៤ ទំព័រ ៣។ តែរយៈពេល ២២ ខែក្រោយមក អង្គជំនុំជម្រះសាលាដំបូងI បានយល់ឃើញថាជនជាប់ចោទ*Kovačević* "មិនមានសមត្ថភាពក្នុងការផ្តល់ចម្លើយ និងចូលរួមសវនាការ ដោយមិនប៉ះពាល់ដល់[illegible] ការនីតិវិធីព្រហ្មទណ្ឌនាពេលខាងមុខប្រឆាំងនឹងរូបគាត់ឡើយប្រសិនបើស្ថានភាពសុខភាពរបស់គាត់មានការប្រែប្រួល"[illegible] សាលាដំបូងI ចុះថ្ងៃទី២ ខែមិថុនា ឆ្នាំ២០០៤ ទំព័រ ១២។ ហេតុដូច្នេះ អង្គជំនុំជម្រះសាលាដំបូងI បដិសេធសំណើរ[illegible]

ជាថ្មីម្តងទៀត "ការដោះលែងបណ្តោះអាសន្ន" ក្នុងន័យនេះ មិនមែនសំដៅដោះលែងជនជាប់ចោទឱ្យមានសេរីភាពនោះទេ ប៉ុន្តែគ្រាន់តែបញ្ឈប់ការឃុំខ្លួនរបស់តុលាការ ICTY ដោយសារតែការអនុវត្តវិធានការឃុំខ្លួននៅខាងក្រៅយុត្តាធិការរបស់តុលាការ ICTY។

២៣ ទាក់ទងនឹងបញ្ហាជាក់លាក់នៃការឃុំខ្លួនក្នុងអំឡុងពេលផ្អាកកិច្ចដំណើរការនីតិវិធី *រឿងក្តី Lubanga Dyilo* នៅតុលាការព្រហ្មទណ្ឌអន្តរជាតិគឺជាគំរូមួយ។ នៅថ្ងៃទី ១៣ ខែមិថុនា ឆ្នាំ២០០៨ អង្គជំនុំជម្រះសាលាដំបូង I នៅតុលាការព្រហ្មទណ្ឌអន្តរជាតិ បានផ្អាកកិច្ចដំណើរការនីតិវិធីនៅក្នុង*រឿងក្តី Lubanga Dyilo* ដោយសារ "រដ្ឋអាជ្ញាមិនបានបង្ហាញឯកសារមួយចំនួនដល់មេធាវីការពារក្តី ដែលធ្វើឱ្យមិនអាចមានការជំនុំជម្រះដោយយុត្តិធម៌"[77]។ នៅថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០០៨ អង្គជំនុំជម្រះសាលាដំបូងI បានបង្គាប់ឱ្យដោះលែងជនជាប់ចោទដោយគ្មានលក្ខខណ្ឌ[78]។ នៅក្នុងដំណាក់ប្តឹងសាទុក្ខ អង្គជំនុំជម្រះតុលាការកំពូលបានសម្រេចថា សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងឱ្យដោះលែង Lubanga មានកំហុស ពីព្រោះថា៖

> នៅពេលបង្គាប់ឱ្យដោះលែងលោក Lubanga Dyilo ដោយគ្មានលក្ខខណ្ឌ អង្គជំនុំជម្រះសាលាដំបូងមិនបានពិចារណាលើចរិតលក្ខណៈនៃការផ្អាកកិច្ចដំណើរការនីតិវិធីដោយមានលក្ខខណ្ឌ ដែលខ្លួនត្រូវដាក់ឱ្យបានត្រឹមត្រូវនោះទេ។ ករណីនេះនាំឱ្យអង្គជំនុំជម្រះសាលាដំបូងខកខានមិនបានពិចារណាលើជម្រើស

សុំឱ្យច្រានចោលដីកាបញ្ជូនរឿងទៅជំនុំជម្រះ។ (IT-01-42/2-I "សេចក្តីសម្រេចស្តីពីសំណើរបស់មេធាវីការពារក្តីសុំបញ្ជាក់ពីការបណ្តឹងសាទុក្ខបន្ទាន់បង្ខំប្រឆាំងនឹងសេចក្តីសម្រេចស្តីពីសំណើរបស់មេធាវីការពារក្តីសុំច្រានចោលដីការបញ្ជូនរឿងទៅជំនុំជម្រះ ចាប់ពីថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០០៦"ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០០៦ (ដែលបានបដិសេធសំណើសុំការបញ្ជាក់ពីការប្តឹងឧទ្ធរណ៍លើសេចក្តីសម្រេចបដិសេធសំណើរបស់មេធាវីការពារក្តីសុំបដិសេធចោលដីកាបញ្ជូនរឿងទៅជំនុំជម្រះ)។ ទីបំផុត សំណុំរឿង ត្រូវបានបញ្ជូនទៅអាជ្ញាធរសមត្ថកិច្ចនៃសាធារណរដ្ឋស៊ែបIT-01-42/2-I "សេចក្តីសម្រេចលើបណ្តឹងសាទុក្ខប្រឆាំងនឹងសេចក្តីសម្រេចស្តីពីការបញ្ជូនសំណុំរឿងតាមវិធាន ១១*ស្ទួន*' អង្គជំនុំជម្រះតុលាការកំពូល ថ្ងៃទី២៨ ខែមីនា ឆ្នាំ២០០៧)។

[77] នៅក្នុងរឿងក្តី *Lubanga*, App. Ch., ICC-01/04-01/06-1486 "សាលក្រមលើបណ្តឹងសាទុក្ខរបស់រដ្ឋអាជ្ញាប្រឆាំងនឹង សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង Iហៅថា 'សេចក្តីសម្រេចស្តីពីផលវិបាកនៃពីផលវិបាកនៃការមិនបង្ហាញវត្ថុតាងដោះបន្ទុកដោយអនុលោមតាមមាត្រា៥៤(៣)(ង) នៃកិច្ចព្រមព្រៀង និងការអនុវត្តក្នុងការផ្អាកការចោទប្រកាន់ជនជាប់ចោទ ជាមួយនឹងបញ្ហាមួយចំនួនដទៃទៀត ដែលបានលើកឡើងនៅក្នុងកិច្ចប្រជុំស្តីឋានៈ នៅថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៨"" អង្គជំនុំជម្រះតុលាការកំពូល ថ្ងៃទី២១ ខែតុលា ឆ្នាំ២០០៨ កថាខណ្ឌ ៦។

[78] រឿងក្តី *Lubanga*, App. Ch., ICC-01/04-01/06-1418 " សេចក្តីសម្រេចស្តីពីការដោះលែងជនជាប់ចោទ Thomas Lubanga Dyilo" អង្គជំនុំជម្រះតុលាការកំពូល ថ្ងៃទី២១ ខែតុលា ឆ្នាំ២០០៨ កថាខណ្ឌ ៣០-៣៦។

ទាំងអស់តាមឆន្ទានុសិទ្ធិរបស់ខ្លួន និងបានសន្និដ្ឋានដោយមិនត្រឹមត្រូវថា ការដោះលែងលោក Lubanga Dyilo ដោយគ្មានលក្ខខណ្ឌ គឺជម្រើស "មិនអាចជៀសរួច"[79]។

២៤ ចំណុចសំខាន់ផ្សេងទៀតចំពោះរឿងក្តីនេះ អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការព្រហ្មទណ្ឌអន្តរជាតិ បានសម្រេចថា អង្គជំនុំជម្រះសាលាដំបូង I មិនមានកំហុសក្នុងការសម្រេចថា នៅពេលអង្គជំនុំជម្រះសម្រេចពន្យារកិច្ចដំណើរការនីតិវិធីនោះ គឺ "មិនមានសង្ឃឹមថាអាចមានការជំនុំជម្រះប្រកបដោយយុត្តិធម៌នោះទេ"[80]។ ប៉ុន្តែ ទោះបីជានៅក្នុងកាលៈទេសៈបែបនោះក្តី "តុលាការមិនចាំបាច់ហាមឃាត់មិនឱ្យអនុវត្តយុត្តាធិការជាអចិន្ត្រៃយ៍ដែលពាក់ព័ន្ធនឹងបុគ្គលនោះទេ" ពីព្រោះចរិតនៃការផ្អាកកិច្ចដំណើរការនីតិវិធីដែលបង្គាប់ដោយអង្គជំនុំជម្រះសាលាដំបូង គឺមានលក្ខខណ្ឌ និងអាចបដិសេធចោលបាន[81]។ ហេតុដូច្នេះ៖

នៅពេលអង្គជំនុំជម្រះបង្គាប់ឱ្យផ្អាកកិច្ចដំណើរការនីតិវិធីដោយមានលក្ខខណ្ឌ ការដោះលែងបុគ្គលដែលពាក់ព័ន្ធដោយគ្មានលក្ខខណ្ឌ គឺមិនមែនជាផលវិបាកដែលមិនអាចជៀសរួចនោះទេ។ ប៉ុន្តែ អង្គជំនុំជម្រះនឹងពិចារណាលើកាលៈទេសៈពាក់ព័ន្ធទាំងអស់ និងផ្អែកការសម្រេចឱ្យដោះលែង ឬឃុំខ្លួន ផ្អែកតាមលក្ខណៈវិនិច្ឆ័យដែលមានចែងនៅក្នុងមាត្រា ៦០ និង ៥៨(១) នៃលក្ខន្តិកៈ។ ជាពិសេស ភាពចាំបាច់នៃការបន្តការឃុំខ្លួន (សូមមើល មាត្រា ៥៨ (១) (ខ) នៃលក្ខន្តិកៈ) ត្រូវតែវាយតម្លៃដោយយកចិត្តទុកដាក់។ ដោយយោងតាមមាត្រា ៥៨ (១)(ខ)(i) នៃលក្ខន្តិកៈ អង្គជំនុំជម្រះត្រូវពិចារណាថា ការជំនុំជម្រះអាចផ្អាកដោយមានលក្ខខណ្ឌ មិនមែនត្រូវបញ្ឈប់ជាអចិន្ត្រៃយ៍នោះទេ។ ប្រសិនបើលក្ខខណ្ឌនៃការបន្តការឃុំខ្លួន មិនបានបំពេញ អង្គជំនុំជម្រះនឹងត្រូវកំណត់ថាតើ នៅក្នុងកាលៈទេសៈពិសេសនៃរឿងក្តី ការដោះលែងគួរតែមានលក្ខខណ្ឌ ឬដោយគ្មានលក្ខខណ្ឌ (សូមមើលមាត្រា ៦០(២) ប្រយោគទីបីនៃលក្ខន្តិកៈ)...ក្នុងពេលជាមួយគ្នានោះ អង្គជំនុំជម្រះត្រូវតែពិចារណាដោយប្រុងប្រយ័ត្នថា ការបន្តការឃុំខ្លួនណាមួយ មិនត្រូវឃុំខ្លួនក្នុងរយៈពេលវែងដោយមិនសមហេតុផលនោះទេ ដែលជាការបំពារបំពានលើសិទ្ធិមនុស្សដែលទទួលស្គាល់ជាអន្តរជាតិ (សូម

[79] រឿងក្តី *Lubanga*,App. Ch., ICC-01/04-01/06-1487 " សាលក្រមលើបណ្តឹងសាទុក្ខរបស់រដ្ឋអាជ្ញាប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង I ហៅថា "សេចក្តីសម្រេចស្តីពីការដោះលែងជនជាប់ចោទThomas Lubanga Dyilo"" អង្គជំនុំជម្រះតុលាការកំពូល ថ្ងៃទី២១ ខែតុលា ឆ្នាំ២០០៨ កថាខណ្ឌ៣១។

[80] រឿងក្តី *Lubanga*,App. Ch., ICC-01/04-01/06-1487 " សាលក្រមលើបណ្តឹងសាទុក្ខរបស់រដ្ឋអាជ្ញាប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង I ហៅថា "សេចក្តីសម្រេចស្តីពីការដោះលែងជនជាប់ចោទThomas Lubanga Dyilo"" អង្គជំនុំជម្រះតុលាការកំពូល ថ្ងៃទី២១ ខែតុលា ឆ្នាំ២០០៨ កថាខណ្ឌ ៣២។

[81] រឿងក្តី *Lubanga*,App. Ch., ICC-01/04-01/06-1487 " សាលក្រមលើបណ្តឹងសាទុក្ខរបស់រដ្ឋអាជ្ញាប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង I ហៅថា "សេចក្តីសម្រេចស្តីពីការដោះលែងជនជាប់ចោទ Thomas Lubanga Dyilo"" អង្គជំនុំជម្រះតុលាការកំពូល ថ្ងៃទី២១ខែតុលាឆ្នាំ២០០៨កថាខណ្ឌ ៣៧។

SUPREME COURT CHAMBER CHAMBRE DE LA COUR SUPRÊME * E.C.C.C * C.E.T.C *

មើលមាត្រា ៩(៣) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៦៦) មាត្រា៥(៣) នៃអនុសញ្ញាសម្រាប់ការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋានចុះថ្ងៃទី៤ ខែវិច្ឆិកា ឆ្នាំ១៩៥០ និងមាត្រា៧(៥) នៃអនុសញ្ញាអាមេរិកស្តីពីសិទ្ធិមនុស្សចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ១៩៦៩។ សូមមើលផងដែរ មាត្រា៧(១) នៃធម្មនុញ្ញអាហ្វ្រិកស្តីពីសិទ្ធិមនុស្ស និងសិទ្ធិពលរដ្ឋចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ១៩៨១ ដែលចែងជាទូទៅអំពីសិទ្ធិក្នុងការទទួលបានការជំនុំជម្រះក្នុងពេលវេលាសមស្រប)។ ប្រសិនបើអង្គជំនុំជម្រះសន្និដ្ឋានថា ការបន្តការឃុំខ្លួន ឬការដោះលែងដោយមានលក្ខខណ្ឌ គឺត្រឹមត្រូវតាមច្បាប់អង្គជំនុំជម្រះនឹងត្រូវពិនិត្យមើលឡើងវិញលើសេចក្តីសម្រេចនេះក្នុងរយៈពេលខ្លីខាងមុខ[82]។

២៥ យុត្តិសាស្ត្រអន្តរជាតិដូចង្គល់បង្ហាញខាងលើបង្ហាញថា ការដោះលែងដោយគ្មានលក្ខខណ្ឌ គឺមិនមែនជាជម្រើសតែមួយគត់ដែលមាននៅក្នុងតុលាការព្រហ្មទណ្ឌដែលបានផ្អាក ឬ ពន្យាកិច្ចដំណើរការនីតិវិធីដោយសារតែឧបសគ្គមួយដែលអាចនឹងដោះស្រាយបាននៅពេលខាងមុខ ប៉ុណ្ណោះទេ។ ការមិនមានសមត្ថភាព ឬឧបសគ្គធ្ងន់ធ្ងរដទៃទៀតដែលរាំងស្ទះដល់កិច្ចដំណើរការនីតិវិធី មិនមែនធ្វើឲ្យតុលាការមិនអាចយកវិធានការដទៃទៀតមកអនុវត្តបាន ដូចជាការបន្តឃុំខ្លួនដែលធ្វើក្នុងគោលបំណងធានាវត្តមានរបស់ជនជាប់ចោទនៅពេលជំនុំជម្រះនោះទេ។ ទាក់ទងនឹងសម្បទាក្នុងការចូលរួមសវនាការរបស់ជនជាប់ចោទត្រូវបានចោទជាសំណួរ ឬមានកង្វះខាត ការដាក់ឲ្យឃុំខ្លួនដោយមានការព្យាបាលជាចាំបាច់ ត្រូវបានចាត់ទុកជាឧបករណ៍សម្រាប់គោលបំណងបន្តកិច្ចដំណើរការនីតិវិធី។ បន្ថែមពីលើនេះ ការដោះលែងដោយគ្មានលក្ខខណ្ឌ ត្រូវបានអនុវត្តក្នុងករណីលើកលែងតែប៉ុណ្ណោះ ដោយផ្អែកលើមូលហេតុមនុស្សធម៌នៅក្នុងករណីស្ថានភាពចុងក្រោយពិសេស ។ នៅក្នុងរឿងក្តីបច្ចុប្បន្ននេះ អង្គជំនុំជម្រះសាលាដំបូងយោងទៅលើ "បទប្បញ្ញត្តិទូទៅមិនជាក់លាក់មួយ នៃច្បាប់ស្តីពីសិទ្ធិមនុស្ស និងព្រហ្មទណ្ឌអន្តរជាតិ" ធ្វើជាមូលដ្ឋានក្នុងការសន្និដ្ឋានរបស់ខ្លួនថា "បទដ្ឋានអន្តរជាតិជាមូលដ្ឋានខាងលើ តម្រូវឲ្យមានការដោះលែងជនជាប់ចោទ អៀង ធីរិទ្ធ ដោយគ្មានលក្ខខណ្ឌ"[83]។ ផ្ទុយទៅវិញ ដូចដែលបានបង្ហាញនៅក្នុងតុលាការព្រហ្មទណ្ឌអន្តរជាតិ ក៏ដូចជានៅក្នុងតុលាការមិនអចិន្ត្រៃយ៍នានា ការដោះលែងជនជាប់ចោទដោយគ្មានលក្ខខណ្ឌ គឺមិន "តម្រូវឲ្យមាន" ឡើយនៅក្នុងបរិបទនៃការផ្អាកដំណើរការនីតិវិធីដែល

---

[82]រឿងក្តី *Lubanga*,App. Ch., ICC-01/04-01/06-1487 " សាលក្រមលើបណ្តឹងសាទុក្ខរបស់រដ្ឋអាជ្ញាប្រឆាំងនឹងសេចក្តីសម្រេច របស់អង្គជំនុំជម្រះសាលាដំបូង I ហៅថា "សេចក្តីសម្រេចស្តីពីការដោះលែងជនជាប់ចោទThomas Lubanga Dyilo"" អង្គជំនុំជម្រះតុលាការកំពូល ថ្ងៃទី២១ខែតុលាឆ្នាំ២០០៨កថាខណ្ឌ ៣៧។

[83] សេចក្តីសម្រេចដែលរងការជំទាស់ កថាខណ្ឌ ៨០។

អាចបន្តនីតិវិធីទៀតបាន។ យុត្តិសាស្ត្ររបស់តុលាការជាតិមួយចំនួន មានបញ្ញត្តិចែងប្រហាក់ប្រហែលគ្នានេះដែរ[84]។

២៦ ឧបសគ្គចំពោះការបន្តកិច្ចដំណើរការនីតិវិធីប្រឆាំងនឹងជនជាប់ចោទ គឺការរកឃើញរបស់អង្គជំនុំជម្រះសាលាដំបូងដែលថាអ្នកស្រីមិនមានសម្បទាដើម្បីចូលរួមសវនាការបានឡើយ នៅពេលនេះ។ អង្គជំនុំជម្រះសាលាដំបូងពិចារណាថា ឧបសគ្គនេះគឺមានលក្ខណៈជាលក្ខខណ្ឌដែល លក្ខខណ្ឌនេះអាចត្រូវដកចេញបាននៅពេលអនាគត។ តាមរយៈគោលបំណងនៃការចេញដីកាបង្គាប់ឲ្យផ្ទេរជនជាប់ ចោទទៅមន្ទីរពេទ្យដើម្បីទទួលការព្យាបាលនោះ មតិភាគច្រើននៃសេចក្តីសម្រេចដីការជំទាស់ បានពិចារណាថា ការផ្អាកកិច្ចដំណើរការនីតិវិធីអាចត្រូវលុបចោល ប្រសិនបើស្ថានភាពរបស់ជនជាប់ចោទ មានលក្ខណៈល្អប្រសើរគ្រប់គ្រាន់។ ទោះបីជាមតិភាគតិចបានពិចារណាថា "ការផ្អាកកិច្ចដំណើរការនីតិវិធីដែលសម្រេចដោយអង្គជំនុំជម្រះទំនងជាមានលក្ខណៈអចិន្ត្រៃយ៍ក៏ដោយ"[85] ក៏ពួកគាត់ បានយល់ស្របទៅនឹងផ្នែកសម្រេចសេចក្តីនៅក្នុងសេចក្តីសម្រេចឲ្យដោះលែងដែលជាផ្នែកមានដូចខាងក្រោមនេះ៖

> ជំរាបមកសហព្រះរាជអាជ្ញាថា សហព្រះរាជអាជ្ញា អាចស្នើសុំឲ្យអង្គជំនុំជម្រះចាត់តាំងអ្នក ជំនាញឲ្យធ្វើការវាយតម្លៃជនជាប់ចោទ អៀង ធីរិទ្ធ ឡើងវិញ តាមរយៈកាល និងអាចស្នើសុំឲ្យអង្គជំនុំជម្រះចាប់ផ្តើមដំណើរការនីតិវិធីចំពោះជនជាប់ចោទ អៀង ធីរិទ្ធ នៅដំណាក់កាលណាមួយក៏បាន នៅពេលដែលមានការបង្ហាញថា ស្ថានភាពសុខភាពរបស់ជនជាប់ចោទ មានការផ្លាស់ប្តូរ។ ដើម្បីសម្រេចគោលដៅនេះ សហព្រះរាជអាជ្ញាត្រូវបង្កើតយន្តការត្រួត ពិនិត្យស្ថានភាពសុខភាពរបស់ជនជាប់ចោទជាប្រចាំ[86]។

---

[84] សូមមើល ឧទាហរណ៍ មាត្រា៣៧៦(២) នៃក្រមនីតិវិធីព្រហ្មទណ្ឌប្រទេសសិរីលង្ការ (ដែលចែងពីលទ្ធភាពនៃការឃុំឃាំងជនជាប់ចោទ នៅក្នុងមន្ទីរពេទ្យផ្លូវចិត្ត ឬទីកន្លែងសមស្របដទៃទៀត ដើម្បីឃុំឃាំងដោយសុវត្ថិភាព ប្រសិនបើរកឃើញថា ជនជាប់ចោទនោះមានបញ្ហាផ្លូវចិត្តមិនប្រក្រតី ហើយមិនអាចធ្វើការការពារខ្លួនបាន ហើយរឿងក្តីនោះមិនអាចឲ្យមានការត្រួតពិនិត្យតាមផ្លូវតុលាការបាន ឬក្នុងករណីដែលមិនអាចផ្តល់សន្តិសុខឲ្យបានគ្រប់គ្រាន់) មាត្រា៧៣ និង ២៨៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌប្រទេសអ៊ីតាលី (ផ្តល់អំណាចដល់ចៅក្រម ក្នុងការបង្គាប់ឲ្យឃុំខ្លួនជនជាប់ចោទជាបណ្តោះអាសន្ន នៅក្នុងកន្លែងព្យាបាលវិកលចរិត ហើយអនុវត្តនូវគ្រប់វិធានការណ៍ដែលចាំបាច់ ដើម្បីរាំងនូវរាល់ហានិភ័យនៃការរត់គេច) មាត្រា ១០១ នៃក្រមនីតិវិធីព្រហ្មទណ្ឌប្រទេសកូរ៉េខាងត្បូង (បញ្ជាក់ថាតុលាការអាចពន្យាការឃុំឃាំង ហើយដាក់ជនជាប់ចោទនៅក្នុងស្ថាប័នដែលមានការការពារ) ជំពូក១៧, ១៦០-១៦៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌប្រទេស Zambia, *Jackson v. Indiana*, 406 U.S. 715 (1972);មាត្រា ២៥៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ប្រទេសប៉ូឡូញ (ចែងថាការព្យួរដំណើរការនីតិវិធី មិនបានរាំងមិនឲ្យមានការអនុវត្តនូវមធ្យោបាយបណ្តោះអាសន្ន ដែលរួមមានការឃុំខ្លួន ឬការដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ដែលធ្វើឡើងដើម្បីធានាថា ជនជាប់ចោទមានវត្តមានក្នុងការជំនុំជម្រះ)។

[85]សេចក្តីសម្រេចដែលរងការជំទាស់ កថាខណ្ឌ ៧៤។

[86]សេចក្តីសម្រេចដែលរងការជំទាស់ កថាខណ្ឌ ៣០។

00759896



២៧ "ការជំរាប" មកសហព្រះរាជអាជ្ញាថា សហព្រះរាជអាជ្ញា "អាចស្នើសុំឲ្យចាប់ផ្តើមដំណើរការនីតិវិធីប្រឆាំងនឹង អៀង ធីរិទ្ធ ឡើងវិញ សន្មតជាមុននូវលទ្ធភាពដែលថា ឧបសគ្គដែលធ្វើឲ្យមានការផ្អាកនេះ អាចត្រូវបានដកចេញនៅពេលអនាគត។ យោងទៅលើមតិភាគតិច ទោះបីជា "ទំនងជាមិនមានហេតុផលសមស្របដើម្បីជំនុំជម្រះជនជាប់ចោទបានក៏ដោយ"[87] តាមលក្ខណៈទ្រឹស្តី ការផ្អាកកិច្ចដំណើរការនីតិវិធី អាចត្រូវបានលុបចេញនៅពេលអនាគត ប្រសិនបើជនជាប់ចោទអាច មានសម្បទាល្អប្រសើរឡើងវិញក្នុងការចូលរួមសវនាការ។

២៨ ទោះបីជាមានការយល់ស្របជាឯកច្ឆន្ទនៅក្នុងអង្គជំនុំជម្រះសាលាដំបូងទៅលើលទ្ធភាពដែលថា ជនជាប់ចោទ អាចមានសម្បទាចូលរួមសវនាការក៏ដោយ ក៏អង្គជំនុំជម្រះសាលាដំបូងពុំបានភ្ជាប់នូវលក្ខខណ្ឌទៅការផ្អាកកិច្ចដំណើរការនីតិវិធីប្រឆាំងនឹងជនជាប់ចោទ ដូច្នេះ បានប្រមើលមើលនូវការខិតខំប្រឹងប្រែងណាមួយក្នុងការបន្តកិច្ចដំណើរការនីតិវិធីឡើងវិញ ប្រឆាំងនឹងជនជាប់ចោទ។ លទ្ធផលបែបនេះ នឹងមិនត្រូវគ្នាជាមួយនឹងផលប្រយោជន៍យុត្តិធម៌ ពីគ្រប់ទស្សនទាំងអស់ឡើយ រួមមាន ជនជាប់ចោទ អយ្យការ ដើមបណ្តឹងរដ្ឋប្បវេណី និងសង្គមកម្ពុជាទាំងមូល។ ដើម្បីជាប្រយោជន៍ក្នុងការចោទប្រកាន់ អង្គជំនុំជម្រះនេះ យល់ស្របជាមួយនឹងទឡ្ហីករណ៍របស់សហព្រះរាជអាជ្ញាអំពីអត្ថិភាពនៃផលប្រយោជន៍សាធារណៈ ("សិទ្ធិជំទាស់ និងផលប្រយោជន៍ផ្លូវច្បាប់ដែល ពាក់ព័ន្ធ")[88] ក្នុងការប្តឹងចោទប្រកាន់ជនជាប់ចោទ។ អត្ថិភាពតែមួយគត់របស់តុលាការនេះ និងកិច្ចខិតខំជាបន្តបន្ទាប់របស់ខ្លួនតាមរយៈដំណើរការចរចាជាគំនិតមួយ និងប្រតិបត្តិការជាបន្តបន្ទាប់របស់ខ្លួនជាស្ថាប័នមួយ គឺជាសក្ខីភាពចំពោះផលប្រយោជន៍សាធារណៈដ៏ធំធេង នៅក្នុងការកាត់សេចក្តីបុគ្គលទាំងឡាយ និងឧក្រិដ្ឋកម្មនៅក្នុងយុត្តាធិការរបស់ខ្លួន ដើម្បីទប់ស្កាត់នូវនិទណ្ឌភាព និងជំរុញនូវការផ្សះផ្សារជាតិ។ ដោយសារកិច្ចដំណើរការនីតិវិធីដែលបានធ្វើកន្លងមក ដែលបទចោទប្រឆាំងនឹងជនជាប់ចោទ ត្រូវបានកំណត់ឡើងដោយអង្គបុរេជំនុំជម្រះ ដូច្នេះ កត្តាទាំងនេះមានអត្ថប្រយោជន៍ដ៏ចាំបាច់ជាសាធារណៈ ក្នុងការចោទប្រកាន់ជនជាប់ចោទ។ បន្ថែមលើនេះទៀត ដោយហេតុថា ជនជាប់ចោទមិនត្រូវបានរកឃើញថាមានកំហុសយ៉ាងហោចណាស់ ក្នុងន័យអរូបី មានអត្ថប្រយោជន៍ផ្នែកច្បាប់ដល់ជនជាប់ចោទក្នុងការសំអាងលើគោលការណ៍សន្មតទុកជាមុនថាគ្មានទោស និងការធ្វើបណ្តឹងសាទុក្ខប្រឆាំងនឹងការផ្អាកកិច្ចដំណើរការ

[87]សេចក្តីសម្រេចដែលរងការជំទាស់ កថាខណ្ឌ ៧៨។

[88]សារណាបន្ថែម កថាខណ្ឌ ២៥។

នីតិវិធី។ មានអត្ថប្រយោជន៍ផងដែរដល់ជនរងគ្រោះក្នុងការស្វែងរកការពិត និងទាមទារសំណង រដ្ឋប្បវេណី។

២៩ នៅពេលមានអត្ថប្រយោជន៍ដើម្បីយុត្តិធម៌នោះ បន្ទាប់ពីរកឃើញថាមិនមានសម្បទា តុលាការត្រូវចាត់វិធានការដោះស្រាយ។ ប៉ុន្តែ យន្តការមួយដែលមានគោលបំណងដោះស្រាយឧបសគ្គដល់ កិច្ចដំណើរការនីតិវិធីប្រឆាំងនឹងជនជាប់ចោទ មិនបានលើកឡើងនៅក្នុងសេចក្ដីសម្រេចបង្គាប់ឲ្យដោះលែង ជនជាប់ចោទ នោះទេ។ ជាពិសេស អង្គជំនុំជម្រះសាលាដំបូងខកខានពុំបានផ្ដល់នូវបទបញ្ញត្តិណាមួយទាក់ទិននឹងរបៀបថាតើ អង្គជំនុំជម្រះនឹងធ្វើការពិនិត្យឡើងវិញតាមរយៈកាលលើការផ្អាកនេះ យ៉ាងដូចម្ដេចដើម្បីកំណត់ថាតើជនជាប់ចោទមានសម្បទាល្អឡើងវិញដើម្បីចូលរួមក្នុងសវនាការ។ ផ្ទុយទៅវិញ អង្គជំនុំជម្រះសាលាដំបូងបានបំណងផ្ទេរការទទួលខុសត្រូវរបស់ខ្លួនទៅឲ្យសហព្រះរាជអាជ្ញា នៅពេលដែលអង្គជំនុំជម្រះបាន “ជំរាប” មកសហព្រះរាជអាជ្ញាថា សហព្រះរាជអាជ្ញា “ត្រូវបង្កើតយន្តការត្រួតពិនិត្យ” ឧបសគ្គចំពោះដំណើរការនីតិវិធី ពោលគឺ “ស្ថានភាពសុខភាពរបស់ជនជាប់ចោទជាប្រចាំ”[89]។ នៅពេលដែលទទួលបានដីកាបញ្ជូនរឿងទៅជំនុំជម្រះ អង្គជំនុំជម្រះសាលាដំបូងតែម្នាក់ឯងមានអំណាចបង្កើត និងអនុវត្តយន្តការបែបនេះ ពីព្រោះអង្គជំនុំជម្រះសាលា ដំបូងតែម្នាក់ឯងមានយុត្តាធិការលើជនជាប់ចោទ[90]។ ការផ្ទេរតួនាទីនេះរបស់អង្គជំនុំជម្រះសាលាដំបូង ទៅឲ្យសហព្រះរាជអាជ្ញានៅក្នុងសេចក្ដីសម្រេចដែលរងការជំទាស់គឺផ្ទុយទៅនឹងស្មារតីនៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា និងនីតិវិធីដែលពាក់ព័ន្ធ ដែលបង្កើតឡើងនៅកម្រិតអន្តរជាតិ។ លើសពីនេះទៀត ទោះបីអង្គជំនុំជម្រះសាលាដំបូង មិនបានកំណត់នូវបទដ្ឋាននៃភស្តុតាងដែលខ្លួនប្រើប្រាស់ក្នុងការវាយតម្លៃលើក្ដីសង្ឃឹម ដែលធ្វើឲ្យស្ថានភាពរបស់ជនជាប់ចោទបានប្រសើរឡើងក៏ដោយ ក៏បទដ្ឋាននេះទំនងជាមានលក្ខណៈខ្ពស់ពេកសម្រាប់គោលបំណងនៃការពិចារណាជាពិសេសនេះ។ អង្គជំនុំជម្រះសាលាតុលាការកំពូលសម្រេចថា ដោយពិចារណាលើអត្ថប្រយោជន៍នៃយុត្តិធម៌ក្នុងការជំនុំជម្រះក្ដីជនជាប់ចោទ បន្ទាប់ពីរកឃើញថាគ្មាន

---

[89] សេចក្ដីសម្រេចដែលរងការជំទាស់ កថាខណ្ឌ 30។

[90] នៅកម្រិតអន្តរជាតិ មានតែចៅក្រមក្រុមប្រឹក្សាជំនុំជម្រះប៉ុណ្ណោះ ដែលអាចបង្គាប់ឲ្យមានការផ្អាក ហើយមានតែចៅក្រមក្រុមប្រឹក្សាជំនុំជម្រះប៉ុណ្ណោះដែលមានអំណាចត្រួតពិនិត្យលើជនជាប់ចោទ ក្នុងពេលដោះលែងជាបណ្ដោះអាសន្ន ហើយនឹងបន្តឡើងវិញនូវដំណើរការនីតិវិធី នៅពេលដែលខ្លួនយល់ឃើញថាជនជាប់ចោទមានសម្បទាគ្រប់គ្រាន់ក្នុងការចូលរួមក្នុងការជំនុំជម្រះ។ សូមមើល ឧទាហរណ៍ រដ្ឋអាជ្ញា តទល់នឹង *Vladimir Kovačević*, IT-01-42/2-I, “សេចក្ដីសម្រេចលើការដោះលែងបណ្ដោះអាសន្ន” អង្គជំនុំជម្រះសាលាដំបូង I ថ្ងៃទី ២ ខែ មិថុនា ឆ្នាំ ២០០៤ ទំព័រ ២។

សម្បទានោះ វិធានការដោះស្រាយត្រូវតែធ្វើឡើងដោយផ្អែកលើលទ្ធភាពដែលអាចមាន ទោះបីជាតិចតួចក៏ដោយក្នុងការធ្វើមានភាពប្រសើរឡើងដោយពិតប្រាកដនោះ[91]។

៣០ ជាសេចក្តីសន្និដ្ឋាន អង្គជំនុំជម្រះតុលាការកំពូល យល់ឃើញថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គច្បាប់ក្នុងការផ្តល់នូវសេចក្តីសន្និដ្ឋានច្បាស់លាស់ ដែលថា "បទដ្ឋានអន្តរជាតិជាមូលដ្ឋានខាងលើទាមទារឲ្យមានការដោះលែងជនជាប់ចោទ អៀង ធីរិទ្ធ ដោយមានគ្មានលក្ខខណ្ឌ"។ សេចក្តីសន្និដ្ឋាននេះពុំត្រូវបានគាំទ្រដោយការអនុវត្តកម្រិតជាតិ ឬអន្តរជាតិឡើយ។ បញ្ហានៃវិធានការសន្តិសុខ ចាំបាច់ត្រូវតែវាយតម្លៃដោយស្របតាមកាលៈទេសៈជាក់លាក់នៃរឿងក្តី និងនៅក្នុងក្របខណ្ឌច្បាប់ដែលជាធរមាន។ ហេតុដូច្នេះ មុនពេលដោះលែងជនជាប់ចោទ អង្គជំនុំជម្រះគួរតែដំបូងបានវាយតម្លៃរាល់អត្ថប្រយោជន៍ និងថ្លឹងថ្លែងឲ្យបានត្រឹមត្រូវរាល់កត្តាពាក់ព័ន្ធ។ ដំណាលពេលនោះដែរ អង្គជំនុំជម្រះសាលាដំបូង ត្រូវតែធ្វើការប្រុងប្រយត្ន័ថា ការបន្តឃុំខ្លួនណាមួយនឹងមិនមែនក្នុងគោលបំណងយូរអង្វែងនោះទេ ដែលជាការរំលោភលើសិទ្ធិមនុស្សដែលត្រូវបានទទួលស្គាល់ជាអន្តរជាតិ។

៣១ យោងតាមសំអាងហេតុខាងលើ អង្គជំនុំជម្រះតុលាការកំពូល ដោយផ្អែកលើអង្គហេតុនៃសំណុំរឿងនេះត្រូវធ្វើការពិនិត្យទៅលើបញ្ហាថាតើ អង្គជំនុំជម្រះសាលាដំបូង មានកំហុស ដែរ ឬយ៉ាងណា ក្នុងការមិនបានផ្តល់នូវវិធានការដោះស្រាយណាមួយ ក្នុងគោលបំណងលុបបំបាត់នូវឧបសគ្គដល់កិច្ចដំណើរការនីតិវិធី និងបញ្ហាថាតើ អង្គជំនុំជម្រះសាលាដំបូង មានកំហុស ដែរ ឬយ៉ាងណា ក្នុងការមិនអនុវត្តនូវវិធានការសុន្តិសុខនានា នោះ។

## ៦.២.២ ថាតើអង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការដោះលែងជនជាប់ចោទដោយគ្មានលក្ខខណ្ឌដែរ ឬយ៉ាងណា៖

[91] រដ្ឋអាជ្ញា តទល់នឹង *Vladimir Kovačević*, IT-01-42/2-I "សេចក្តីសម្រេចលើការដោះលែងបណ្តោះអាសន្ន" អង្គជំនុំជម្រះសាលាដំបូង I ថ្ងៃទី២ ខែ មិថុនា ឆ្នាំ ២០០៤ ទំព័រ១។ (បង្គាប់ឲ្យដោះលែងបណ្តោះអាសន្ន ដោយមានលក្ខខណ្ឌ ផ្អែកលើមូលដ្ឋានវិជ្ជសាស្ត្រ ព្រមទាំង "កត់សម្គាល់ថា នៅក្នុងរបាយការណ៍ដែលបានលើកឡើង បានផ្តល់អនុសាសន៍ថា ជនជាប់ចោទត្រូវតែទទួលបាននូវការព្យាបាលជាបន្ទាន់ នៅកន្លែងព្យាបាលវេជ្ជសាស្ត្រផ្នែកចិត្តសាស្ត្រ នៅទីកន្លែងដែលនិយាយភាសា BCS ហើយដែលការព្យាបាលនេះអាចធ្វើឲ្យស្ថានភាពរបស់ជនជាប់ចោទមានការប្រសើរឡើងជាងមុន..." (ដោយមានការសង្កត់ធ្ងន់)។

៣២ មានការបង្ហាញយ៉ាងច្បាស់ថា មានការខ្វែងគំនិតគ្នារវាងមតិភាគច្រើន និងមតិភាគតិចនៅក្នុងសេចក្តីសម្រេចដែលរងការចោទប្រកាន់ លើបញ្ហាថាតើ ជនជាប់ចោទគួរតែបានដោះលែងដោយមាន ឬពុំមានលក្ខខណ្ឌនោះ គឺកើតចេញពីការខ្វែងគំនិតគ្នាលើបញ្ហាតម្លៃគតិយុត្តពាក់ព័ន្ធទៅនឹងបញ្ហាថាតើជនជាប់ចោទ នៅពេលមានការព្យាបាលបន្ថែមនាពេលអនាគតនោះ អាចមានសម្បទាចូលរួមសវនាការដែរ ឬ យ៉ាងណា។ ដូច្នេះ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថាសមស្រប ក្នុងការពិនិត្យលើបញ្ហានេះ មុនពេលសម្រេចបញ្ហាថាតើ ជនជាប់ចោទគួរតែស្ថិតក្នុងមន្ទីរឃុំឃាំង ឬ ត្រូវដោះលែងដោយមាន ឬ ពុំមានលក្ខខណ្ឌនោះ។

៣៣ សាស្ត្រាចារ្យ A. John Campbell ដែលជាអ្នកជំនាញផ្នែកវេជ្ជសាស្ត្រ ហើយត្រូវបានចាត់តាំងដោយអង្គជំនុំជម្រះសាលាដំបូង បានចេញវេជ្ជបញ្ជាដល់ជនជាប់ចោទឱ្យសាកល្បងប្រើថ្នាំ Donepezil។ សហព្រះរាជអាជ្ញាកត់សម្គាល់ឃើញថា ការចេញវេជ្ជបញ្ជាឱ្យប្រើថ្នាំខាងលើនេះ ត្រូវបានធ្វើឡើង "ដោយពុំមានការមិនយល់ស្រប"[92]ពីអ្នកជំនាញចិត្តសាស្ត្របួនរូបដទៃទៀតឡើយ។ ដូច្នេះការចេញវេជ្ជបញ្ជាគួរតែបានការយល់ព្រមដោយអង្គជំនុំជម្រះសាលាដំបូង[93]។ នៅក្នុងសារណាតប ជនជាប់ចោទលើកឡើងថា សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ដែលមិនអនុញ្ញាតឱ្យធ្វើការសាកល្បងថ្នាំ Donepezil "មានមូលដ្ឋានត្រឹមត្រូវ ដោយបានសំអាងលើកត្តាមួយចំនួន" ដូចជា៖

> ស្ថានភាពជំងឺចេះតែវិវឌ្ឍទៅមុខ ក្តីសង្ឃឹមតិចតួចពីថ្នាំដែលធ្វើឱ្យប្រសើរឡើងវិញបានត្រឹមតែបណ្តោះអាសន្នប៉ុណ្ណោះ ការលំបាកក្នុងការពិនិត្យតាមដាន និងផ្តល់ថ្នាំនៅក្នុងប្រទេសកម្ពុជា និងការពិតដែលថា ការកាត់បន្ថយថ្នាំBenzodiazepine ពុំមានប្រសិទ្ធភាពក្នុងការធ្វើឱ្យការចងចាំ របស់ជនជាប់ចោទបានប្រសើរឡើងវិញឡើយ[94]។

៣៤ សាស្ត្រាចារ្យ Campbell បានពិពណ៌នាថ្នាំ Donepezil ថាមានប្រសិទ្ធភាពតែ "ទៅលើមនុស្សប្រហែលមួយភាគបីប៉ុណ្ណោះដែលប្រើថ្នាំនេះ" ហើយថា ការប្រសើរឡើងវិញជាងមុនណាមួយ ប្រសិនបើមានមែន "ក៏មានត្រឹមតិចតួចប៉ុណ្ណោះ"[95]។ អ្នកជំនាញដទៃទៀតផ្តល់យោបល់ថា ការប្រើថ្នាំ Donepezil "គឺគ្រាន់តែអាចធ្វើឱ្យមានភាពប្រសើរឡើងបន្តិចបន្តួចប៉ុណ្ណោះ ហើយភាពប្រសើរឡើងនេះផ្តល់ផលបានតែ

[92] សេចក្តីសម្រេចដែលរងការជំទាស់ កថាខណ្ឌ ៨០។

[93] សារណាបន្ថែម កថាខណ្ឌ ២០។

[94] ចម្លើយតប កថាខណ្ឌ ៣៧។

[95] សេចក្តីសម្រេចដែលរងការជំទាស់ កថាខណ្ឌ ៣៧។

ទៅលើមនុស្សមួយចំនួនតូចប៉ុណ្ណោះដែលបានប្រើវា"[96]។ អ្នកជំនាញម្នាក់ក្នុងចំណោមអ្នកជំនាញទាំងនេះ គឺវេជ្ជបណ្ឌិត Fazel ដែលបានបញ្ជាក់ថា គាត់"នឹងមិនជំទាស់ជាមួយគាត់ឡើយ [សាស្ត្រាចារ្យ Campbell] [...] ដោយបញ្ជាថា [គាត់] ពុំមាន បទពិសោធន៍ព្យាបាលអ្នកជំងឺដោយប្រើថ្នាំ Donepezil ទេ"[97]។ ប្រការនេះ មិនមែនជាការឯកភាពដ៏ខ្លាំងក្លា ឡើយ[98]។

៣៥ ប៉ុន្តែ អង្គជំនុំជម្រះនេះមិនអាចមិនយកចិត្តទុកដាក់លើ ជំហររបស់សាស្ត្រាចារ្យ Campbell ដែលថា ការសាកល្បងប្រើថ្នាំDonepezil "ចាំបាច់ត្រូវតែសាកល្បង"[99]។ យោបល់របស់វេជ្ជបណ្ឌិត Campbell អំពីប្រសិទ្ធភាពដែលមានចំនួន ៣៣% គឺបង្ហាញអំពីភវនីយភាពដែលមិនគួរត្រូវបានបដិសេធ តាមទស្សនៈនៃផលប្រយោជន៍សាធារណៈនៅក្នុងការកាត់សេចក្តី។ អង្គជំនុំជម្រះសាលាដំបូងយល់ស្របជាមួយនឹងសាស្ត្រាចារ្យ Campbell ថា "យើងមិនអាចកំណត់បានថា ជនជាប់ចោទមិនអាចចូលរួមក្នុងការការពារក្តីរបស់ខ្លួននោះទេ ដរាបណាយើងមិនទាន់បានរិះរកគ្រប់លទ្ធភាព និងព្យាយាមគ្រប់វិធានការក្នុងការសាកល្បង និងធ្វើឱ្យប្រសើរឡើងនោះ"[100]។

៣៦ បន្ថែមលើអនុសាសន៍របស់សាស្ត្រាចារ្យ Campbell ឱ្យសាកល្បងប្រើថ្នាំ Donepezil អ្នកជំនាញផ្នែកវិកលវិទ្យាបានបញ្ជាក់ថាអនុសាសន៍ខាងក្រោមនេះ អាចមានប្រយោជន៍ដល់ជនជាប់ចោទ៖

> ការរក្សាចំនួនបុគ្គលិក និងបុគ្គលិកដដែល ការរក្សាឱ្យមានបរិស្ថានដដែល ការបត់បែនដើម្បីសម្របទៅនឹងលទ្ធភាពប្រែប្រួលរបស់គាត់ ការធ្វើលំហាត់ប្រាណដោយមានការវាយតម្លៃ និងដំបូន្មានពីអ្នកឯកទេសព្យាបាលផ្នែកសរីរៈនៅពេលដែលត្រូវការ និងការគាំទ្រការចូលរួមក្នុងសកម្មភាពដែលគាត់ពេញចិត្ត។ បន្ថែមលើនេះ កម្មវិធីជម្រុញសតិបញ្ញាដែលមានរចនាសម្ព័ន្ធត្រឹមត្រូវអាចជួយបានដែរ (ប៉ុន្តែ កម្មវិធីបែបនេះត្រូវអនុវត្តចំពោះអ្នកដែលបានទទួលការហ្វឹកហាត់ និងស្ថិតនៅក្រោមការត្រួតពិនិត្យ)។ បន្ថែមលើនេះ ការព្យាបាលជង្គង់ និងការឈឺចាប់ខ្នងរបស់លោកស្រី អៀង ធីរិទ្ធ និងការពិនិត្យតាមដានជាប្រចាំទៅលើសុខភាពរាងកាយរបស់គាត់ គឺជាការសំខាន់ដែលត្រូវធ្វើ។ ការបន្តព្យាបាលលើស្ថានភាពវេជ្ជសាស្ត្រពីរដែលមានអត្ថិភាពរួមគ្នានឹងធ្វើឱ្យលទ្ធភាពនៃការជាសះស្បើយរបស់គាត់មានការកើនឡើង។ យើងខ្ញុំកត់សម្គាល់ឃើញថា មិនមានអ្នកជំនាញព្យាបាលតាមបែបឱ្យធ្វើសកម្មភាពពិសេសនោះទេ នៅក្នុងប្រទេស

---

[96]សេចក្តីសម្រេចដែលរងការជំទាស់ កថាខណ្ឌ ៤៦។

[97]ប្រតិចារិក ថ្ងៃទី២០ ខែតុលា ឆ្នាំ២០១១ ទំព័រ៥៤ (ជួរ៦ ដល់៨)។

[98]សូមមើលផងដែរ ប្រតិចារិក ថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១១ ទំព័រ១១១ (ជួរ៨ ដល់១៧)។

[99]ប្រតិចារិក ថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១១ ទំព័រ១៣៨ (ជួរ១៥ ដល់១៦)។

[100]ប្រតិចារិក ថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១១ ទំព័រ៩ (ជួរ១៦ ដល់១៩)។

E.C.C.C * C.E.T.C SUPREME COURT CHAMBER CHAMBRE DE LA COUR SUPRÊME

កម្ពុជា ប៉ុន្តែ ប្រសិនបើមានការវាយតម្លៃលើសកម្មភាពនៃការរស់នៅប្រចាំថ្ងៃរបស់គាត់ អាចមានប្រយោជន៍ ហើយដំបូន្មានស្តីពីការកែសម្រួលណាមួយទៅលើបរិស្ថានរស់នៅរបស់គាត់ គួរត្រូវស្វែងរក[101]។

៣៧ ដោយពិចារណាលើការរកឃើញរបស់អ្នកជំនាញវេជ្ជសាស្ត្រ និង ដោយកត់សម្គាល់លើការកំណត់ពីសម្បទាក្នុងការចូលរួមសវនាការដែលជាបញ្ហាគតិយុត្ត អង្គជំនុំជម្រះតុលាការកំពូល យល់ឃើញថា រាល់វិធានការ ដែលអាចធ្វើបានក្នុងការធ្វើឱ្យសុខភាពស្មារតីរបស់ជនជាប់ចោទប្រសើរឡើងនោះ មិនត្រូវបានរិះរកនោះទេ។ ទោះបីភាពប្រសើរឡើងវិញបានយូរអង្វែង មិនអាចធ្វើទៅបានក៏ដោយ ក៏ដំណើរការនីតិវិធីព្រហ្មទណ្ឌ នៅតែមានអានុភាពដដែល ដោយហេតុថាភាពប្រសើរឡើង អាចកើតមានក្នុងពេលមួយដែលចាំបាច់ ក្នុងការសម្រួលដល់ការជំនុំជម្រះក្តីព្រហ្មទណ្ឌនាពេលបន្ទាប់។ ហេតុដូច្នេះ អង្គជំនុំជម្រះតុលាការកំពូលសម្រេចថា អង្គជំនុំជម្រះសាលាដំបូង មានកំហុសដោយខកខានមិនបានប្រឹងប្រែងឱ្យអស់ពីលទ្ធភាពដែលមានមូលដ្ឋាននៅក្នុងរបាយការណ៍របស់អ្នកជំនាញ ដើម្បីឱ្យសុខភាពស្មារតីរបស់ជនជាប់ចោទប្រសើរឡើង។

៣៨ ដោយពិចារណាឃើញថា ការផ្អាកកិច្ចដំណើរការនីតិវិធីដែលបង្គាប់ដោយអង្គជំនុំជម្រះសាលាដំបូង មិនមែនជាការសម្រេចសេចក្តីដែលមានលក្ខណៈអចិន្ត្រៃយ៍នោះទេ ហើយថា វិធានការរិតត្បិតនានា រួមមានការឃុំខ្លួន មិនត្រូវបានផុតរលត់ឡើយក្នុងពេលផ្អាកនេះ និងបានសន្និដ្ឋានបន្ថែមទៀតថា អ.វ.ត.ក តម្រូវឱ្យប្រើឱ្យអស់នូវរាល់វិធានការដែលអាចមានក្នុងការជួយឱ្យជនជាប់ចោទប្រសើរឡើងដើម្បីចូលរួមសវនាការ ដូច្នេះ អង្គជំនុំជម្រះតុលាការកំពូល នឹងស្រាយបំភ្លឺសំណើរបស់សហព្រះរាជអាជ្ញាសុំឱ្យជនជាប់ចោទស្ថិតក្នុងឃុំ និងទទួលការព្យាបាលផ្នែកវេជ្ជសាស្ត្រ និងផ្នែកលើកកម្ពស់សុខភាពផ្សេងៗទៀត ដោយត្រូវត្រួតពិនិត្យឡើងវិញក្នុងរយៈពេលប្រាំមួយខែ[102]។

៣៩ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា ប្រពន្ធ័ច្បាប់កម្ពុជា ការពារសិទ្ធិសេរីភាព។ តាមច្បាប់កម្ពុជា សេរីភាពរបស់ជនជាប់ចោទ ជាកម្មវត្ថុនៃលក្ខខណ្ឌនៃការឃុំខ្លួនបណ្តោះអាសន្ន[103]។ នៅក្នុង

---

[101]. របាយការណ៍របស់អ្នកជំនាញ វិកលវិទ្យា កថាខណ្ឌ ៣៨។ អង្គជំនុំជម្រះតុលាការកំពូល កត់សម្គាល់ថា មតិភាគច្រើន នៅក្នុងសេចក្តីសម្រេចដែលរងការជំទាស់ យល់ឃើញថា មានកន្លែងព្យាបាល ក៏ដូចជាអ្នកព្យាបាលជំនាញ នៅក្នុងប្រទេសកម្ពុជា ដែលអាចចូលរួមក្នុងការងារនេះ (សូមមើលសេចក្តីសម្រេចដែលរងការជំទាស់ កថាខណ្ឌ ៦៥)។

[102]បណ្តឹងសាទុក្ខ ភ្ជាប់ ១ កថាខណ្ឌ ២។

[103]មាត្រា ២០៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា។

SUPREME COURT CHAMBER CHAMBRE DE LA COUR SUPREME * E.C.C.C * E.T.C

បរិបទ អ.វ.ត.ក សិទ្ធិសេរីភាពនេះ អាស្រ័យលើការប្រែប្រួលលក្ខខណ្ឌដូចគ្នានេះ ដូចដែលមានចែងក្នុងវិធានផ្ទៃក្នុង[104]។ មាត្រា ៩ នៃសន្ធិសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ បានធានានូវសេរីភាព និងជាពិសេស លក្ខខណ្ឌតម្រូវនៃនីត្យានុកូលភាព និងការហាមឃាត់នូវការប្រើអំណាចតាមទំនើងចិត្ត។ ការដកហូតសិទ្ធិសេរីភាពណាមួយមិនត្រូវបានអនុញ្ញាតឡើយ លើកលែងតែមានមូលដ្ឋានដោយអនុលោមតាមនីតិវិធីដែលកំណត់ដោយច្បាប់[105]។ ជនណាដែលត្រូវបានឃុំខ្លួនពីបទព្រហ្មទណ្ឌត្រូវតែទទួលបានការជំនុំជម្រះក្នុងពេលវេលាសមហេតុផល ឬត្រូវបានដោះលែង ហើយមិនមែនជាវិធានទូទៅទេដែលជនណាមួយត្រូវបានឃុំខ្លួនក្នុងមន្ទីរឃុំឃាំងដោយរង់ចាំការជំនុំជម្រះក្តីនោះ[106]។ ប្រហាក់ប្រហែលគ្នានេះដែរ នៅក្នុងប្រព័ន្ធសន្ធិសញ្ញាអឺរ៉ុបស្តីពីសិទ្ធិមនុស្ស សច្ចាធារណ៍ត្រូវបានជាប្រយោជន៍ដល់ការដោះលែង ដូច្នេះ យុត្តិសាស្ត្រនេះ មានលក្ខណៈពាក់ព័ន្ធផងដែរ[107]។ ហេតុដូច្នេះ វិធាន៨២(១) នៃវិធានផ្ទៃក្នុង និងមាត្រា ៣០៥ ដល់ ៣០៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ដែលជាមូលដ្ឋានបង្អែកនៃវិធាននេះ ត្រូវតែពិនិត្យពិចារណាដោយយោងលើសិទ្ធិសេរីភាព។ ផលវិបាកមួយចំនួនដែលកើតចេញពីវិធាននេះ អង្គជំនុំជម្រះតុលាការកំពូលបានបកស្រាយរួចមកហើយ[108]។

៤០ នៅក្នុងរឿងក្តីបច្ចុប្បន្ននេះ អង្គជំនុំជម្រះសាលាដំបូង បានបង្គាប់ឲ្យឃុំខ្លួនជនជាប់ចោទ ដោយសំអាងលើមូលដ្ឋានថា ការឃុំខ្លួនមានលក្ខណៈចាំបាច់ ដើម្បី"ធានាវត្តមានរបស់ជនជាប់ចោទនៅក្នុងដំណើរការនីតិវិធី"[109]។ ពុំមានការបង្ហាញណាមួយនៅក្នុងសេចក្តីសម្រេចដែលរងការជំទាស់ ដែលអង្គជំនុំជម្រះសាលាដំបូងបានពិនិត្យសាឡើងវិញ និងមានបំណងមោឃៈការយល់ឃើញរបស់ខ្លួនពីមុនទាក់ទងនឹងអត្ថិភាពនៃមូលដ្ឋានអង្គហេតុសម្រាប់ធ្វើការឃុំខ្លួនជនជាប់ចោទជាបណ្តោះអាសន្នឡើយ។ ផ្ទុយទៅវិញ ដូចបានលើកឡើងខាងលើ អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការសន្និដ្ឋានថា ខ្លួនមិនមានមូលដ្ឋានក្នុងការឃុំខ្លួនជនជាប់ចោទតទៅទៀត ដែលជាលទ្ធផលនៃការយល់ឃើញពីភាពមិនមានសម្បទា

[104]វិធាន ៦៥៣(៣) នៃវិធានផ្ទៃក្នុង អ.វ.ត.ក។

[105]មាត្រា ៩(1) នៃ ICCPR។

[106]មាត្រា ៩(៣) នៃ ICCPR។

[107].សូមមើល ឧទាហរណ៍ *Kudła v. Poland*, 30210/96 "សាលដីកា" អង្គជំនុំជម្រះតុលាការកំពូល ECtHR ថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ២០០០ កថាខណ្ឌ ១១០ និងបន្តបន្ទាប់។

[108]សាលដីកាលើបណ្តឹងសាទុក្ខភ្លាមៗ របស់ខៀវ សំផន ចំពោះការស្នើសុំឲ្យនៅក្រៅឃុំ ថ្ងៃទី ៦ ខែ មិថុនា ឆ្នាំ ២០១១ E50/3/1/4 កថាខណ្ឌ ៤៧ និង ៤៨។

[109]សេចក្តីសម្រេច លើសំណើប្រញាប់ សុំឲ្យមានការដោះលែងជាបន្ទាន់ ចំពោះ នួន ជា ខៀវ សំផន និង អៀង ធីរិទ្ធ ថ្ងៃទី ... ឆ្នាំ ២០១១, E50, កថាខណ្ឌ ៤១ (ដោយអនុវត្តវិធាន ៦៣(៣)(ខ)(iii))។

ការបំបែកបទចោទ និងការផ្អាកដំណើរការនីតិវិធី។ អង្គជំនុំជម្រះតុលាការកំពូល បានសម្រេចដូចខាងលើថា នៅមុនពេលធ្វើការសន្និដ្ឋាន ថាជនជាប់ចោទមិនមានសម្បទាជាអចិន្ត្រៃយ៍នេះ អង្គជំនុំជម្រះសាលាដំបូងត្រូវតែប្រើប្រាស់នូវរាល់វិធានការដែលមានដោយសមហេតុផល ដែលអាចជួយដល់ជនជាប់ចោទឱ្យមានសម្បទាក្នុងការចូលរួមសវនាការ។ មានលទ្ធភាពមួយដែលអ្នកជំនាញវេជ្ជសាស្ត្រលើកឡើងទាក់ទងនឹងការព្យាបាលដែលនឹងអាចផ្តល់លទ្ធផលយ៉ាងជោគជ័យមួយ។ ក្នុងករណីបែបនេះ ការផ្អាកដំណើរការនីតិវិធី នឹងត្រូវបានផុតរលត់ ហើយដំណើរការនីតិវិធីនឹងត្រូវបន្តទៅតាមការអនុវត្តជាក់ស្តែងតាមដែលអាចធ្វើទៅបាន។

៤១ ហេតុដូច្នេះ មានគោលបំណងពីរដែលត្រូវអនុវត្តក្នុងពេលដំណាលគ្នានេះ។ ទីមួយ គឺភាពចាំបាច់ដែលមានស្រាប់ ដើម្បីធានានូវវត្តមានរបស់ជនជាប់ចោទក្នុងពេលជំនុំជម្រះ ក្នុងពេលឆាប់ៗតាមដែលអាចធ្វើទៅបាន នៅក្នុងពេលបន្តការជំនុំជម្រះឡើងវិញ។ គោលបំណងស្របគ្នាមួយទៀត គឺដើម្បីជម្រុញឱ្យប្រសើរដល់សម្បទារបស់ជនជាប់ចោទ ហើយការព្យាបាលបន្ថែមនិងកម្មវិធី នៃការផ្តល់នូវនីតិសម្បទាត្រូវបានណែនាំក្នុងគោលបំណងនេះ។ ទាក់ទងនឹងគោលបំណងទីមួយ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា មូលដ្ឋានដើមក្នុងការឃុំខ្លួនជនជាប់ចោទ ដើម្បីធានានូវវត្តមានរបស់ជនជាប់ចោទក្នុងដំណើរការនីតិវិធី នៅតែមានសុពលភាព និងពាក់ព័ន្ធដដែរ។ ពុំមានការបង្ហាញណាមួយដែលថាការយល់ឃើញពីភាពមិនមានសម្បទារបស់ជនជាប់ចោទ បានដោះស្រាយទាំងស្រុង ឬជាអចិន្ត្រៃយ៍នូវហានិភ័យរបស់ជនជាប់ចោទមិនអាចចូលរួមក្នុងសវនាការក្នុងពេលអនាគតឡើយ។ ផ្ទុយទៅវិញ នៅពេលពិចារណាពីការបាត់បង់ការចងចាំរបស់ជនជាប់ចោទ ឃើញថាមានហានិភ័យកាន់តែខ្លាំងឡើង ដោយជនជាប់ចោទផ្ទាល់ ប្រហែលជាមិនអាចចូលរួមក្នុងសវនាការបានឡើយ ដោយជនជាប់ចោទមិនទទួលខុសត្រូវចំពោះការខកខានមិនអាចឆ្លើយតបទៅនឹងដីកាកោះនោះ។

៤២ គោលបំណងទីពីរ គឺមាននៅក្នុងភស្តុតាងរបស់អ្នកជំនាញវេជ្ជសាស្ត្រ ដែលថាការសាកល្បងប្រើថ្នាំ Donepezil រួមជាមួយនឹងអនុសាសន៍ដទៃទៀត អាចត្រូវបានរិះរកគ្រប់មធ្យោបាយ ដើម្បីជួយឱ្យសម្បទារបស់ជនជាប់ចោទបានប្រសើរឡើង។ ពុំមានភាពច្បាស់លាស់នៅក្នុងសំណុំរឿងលើបញ្ហាថាតើការដាក់ឃុំក្នុងមន្ទីរពេទ្យ គឺជាករណីចាំបាច់សម្រាប់ការព្យាបាលបែបនេះ ដែរ ឬយ៉ាងណា នោះទេ។ គ្រប់ករណីទាំងអស់ក្នុងការអនុវត្តតាមគោលបំណងនៃការជម្រុញឱ្យបានប្រសើរ តាមគ្រប់មធ្យោបាយការបន្តឃុំខ្លួនជនជាប់ចោទចាំបាច់ត្រូវតែអនុវត្តនៅក្នុងមន្ទីរពេទ្យ ឬកន្លែងប្រហាក់ប្រហែល (វេជ្ជបណ្ឌិត JAYASINGHE ធ្វើយោបល់ជំទាស់)។ កន្លែងប្រហាក់ប្រហែលនេះ អាចធ្វើឡើងនៅក្នុងមន្ទីរពេទ្យយោធា

00759904



អ.វ.ត.ក បន្ទាប់ពីមានការកែប្រែដ៏សមស្រប។ មន្ទីរពេទ្យ ឬកន្លែងប្រហាក់ប្រហែល អាចនឹងអនុញ្ញាតឱ្យមានការផ្ដល់នូវការព្យាបាលដែលមានអនុសាសន៍ប្រកបដោយជំនាញវិជ្ជាជីវៈ និងដោយមានការតាមដាន និងកម្មវិធីផ្ដល់នីតិសម្បទាឡើងវិញ ជាលក្ខណៈមួយប្រកបដោយជំនាញវិជ្ជាជីវៈនិងមានការតាមដាន ហើយ ស្ថិតក្នុងបរិយាកាសមួយដែលត្រូវបានគ្រប់គ្រងដោយតុលាការ ដើម្បីធានានូវប្រសិទ្ធភាពនៃវិធានការនៃការព្យាបាលនេះ ព្រមទាំងការពារសិទ្ធិជនជាប់ចោទ។

៤៣ សំណុំរឿងបង្ហាញថា ការឃុំខ្លួនជនជាប់ចោទក្នុងមន្ទីរពេទ្យ ឬទីកន្លែងប្រហាក់ប្រហែល នឹងមិនបង្កការគំរាមគំហែង ឬបញ្ហាធ្ងន់ធ្ងរដល់សុខភាពផ្លូវកាយ និងផ្លូវចិត្តឡើយ។ ជនជាប់ចោទ មិនមែនស្ថិតក្នុងលក្ខខណ្ឌសុខភាពមួយដែល មិនសមស្របសម្រាប់ការបន្តឃុំខ្លួននោះឡើយ។ ហេតុដូច្នេះ ការព្យាបាលបន្ថែមដែលបានស្នើឡើង មិនមានមូលដ្ឋានលើភាពចាំបាច់ផ្នែកវេជ្ជសាស្ត្របន្ទាន់នោះទេ ប៉ុន្តែ ក្នុងភាពចាំបាច់ត្រូវតែប្រឹងប្រែងឱ្យអស់ពីលទ្ធភាពដើម្បីធ្វើឱ្យសុខភាពស្មារតីរបស់ជនជាប់ចោទបានប្រសើរឡើង។ យោងតាមសំអាងហេតុខាងលើនេះ រឿងក្ដីបច្ចុប្បន្ននេះ មានលក្ខខណៈខុសប្លែកពីយុត្តិសាស្ត្រអន្តរជាតិ ដែលតុលាការព្រហ្មទណ្ឌ បានផ្ដល់ការដោះលែងជាបណ្ដោះអាសន្នដល់ជនជាប់ចោទ ដោយសារមូលហេតុវេជ្ជសាស្ត្រ ឬ មនុស្សធម៌[110]។

## ៦.២.៣ បញ្ហាថាតើអង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការមិនអនុវត្តការត្រួតពិនិត្យតាមផ្លូវតុលាការ ដែរ ឬយ៉ាងណា

៤៤ ដូចដែលបានសម្រេចដោយអង្គជំនុំជម្រះតុលាការកំពូលៈ

> គោលការណ៍ជាសារវន្តគ្រប់គ្រងការឃុំខ្លួនបណ្ដោះអាសន្ន គឺជាគោលការណ៍នៃការសន្មត់ទុកជាមុនដែលបានជាប្រយោជន៍ដល់ការដោះលែង។ ហេតុដូច្នេះ តុលាការដែលវាយតម្លៃពីភាពស្របច្បាប់នៃការឃុំខ្លួនបណ្ដោះអាសន្ន ត្រូវតែវាយតម្លៃរាល់ហេតុផលដែលធានាដល់ការឃុំខ្លួន និងថ្លឹងថ្លែងហេតុផលនេះឱ្យស្របជាមួយនឹងសិទ្ធិសេរីភាពជាមូលដ្ឋានរបស់បុគ្គល។ ដូចដែលតុលាការសិទ្ធិមនុស្សអឺរ៉ុបបានសម្រេចហើយថា ការបន្តឃុំខ្លួនអាចបង្ហាញថាត្រឹមត្រូវតែក្នុងករណីដែលមាន "ការបង្ហាញយ៉ាងជាក់លាក់ពីផលប្រយោជន៍សាធារណៈពិតប្រាកដ..." ដែលមានសារៈសំខាន់ជាងសច្ចាធារណ៍នៃសេរីភាព។ ដូច្នេះ ការបង្ហាញថាមានហានិភ័យក្នុងរត់គេចខ្លួន ការរត់គេចខ្លួន ឬការរាំងដល់ដំណើរការនីតិវិធី មិនមានលក្ខណៈគ្រប់គ្រាន់ឡើយ លើកលែងតែមានមូលដ្ឋានលើកាលៈទេសៈជាក់លាក់នៃរឿងក្ដី

[110] សូមមើល ឧទាហរណ៍ រដ្ឋអាជ្ញា តទល់នឹង *Vladimir Kovačević* ខាងលើ។

ដែលកាលៈទេសៈនេះបានរារាំងការដោះលែង ទោះបីជាដាក់ឲ្យស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការក៏ដោយ[111]។

៤៥ បញ្ហាដែលកើតចេញពីសំណុំរឿងបច្ចុប្បន្ននេះ គឺថាតើ គោលបំណងក្នុងការបន្តឃុំខ្លួន អាចទទួលបានលទ្ធផល តាមរយៈវិធានការដែលពុំសូវរិតត្បិតដូចជាការត្រួតពិនិត្យតាមផ្លូវតុលាការតាមមាត្រា ២២៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា។ នៅក្នុងសេចក្តីសម្រេចដោះលែង មតិភាគតិចបានលើកឡើងថា មាត្រា ២២៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា "អនុញ្ញាតឲ្យមានការត្រួតពិនិត្យតាមផ្លូវតុលាការ ដែលជាជម្រើសក្នុងការឃុំខ្លួនមុនពេលជំនុំជម្រះ" និងមិនយកមកអនុវត្តចំពោះជនជាប់ចោទដែលពុំមានសម្បទា នៅពេលដែលកិច្ចដំណើរការនីតិវិធីត្រូវបានផ្អាក "ដោយពុំមានក្តីសង្ឃឹមសមហេតុផលណាមួយក្នុងការបន្តឡើងវិញ"[112]។ មេធាវីការពារក្តី យល់ស្របទៅនឹងការបកស្រាយនៃមាត្រា២២៣នេះដែរ[113]។ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា មតិភាគតិចនៅក្នុងសេចក្តីសម្រេចដែលរងការជំទាស់មិនមានន័យថា ការត្រួតពិនិត្យតាមផ្លូវតុលាការ មិនមានចំពោះអង្គជំនុំជម្រះសាលាដំបូងនោះទេ ប៉ុន្តែ មិនមាននៅក្នុងកាលៈទេសៈពិសេសទាំងនេះប៉ុណ្ណោះ។ ទោះបីជាយ៉ាងណាក៏ដោយ អង្គជំនុំជ្រះតុលាការកំពូលទទួលយកនូវមតិភាគច្រើននៅក្នុងសេចក្តីសម្រេច ដែលរងការជំទាស់ដែលថា ការត្រួតពិនិត្យតាមផ្លូវតុលាការតាមមាត្រា ២២៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា មាននៅសាលាដំបូងនៅកម្ពុជា និងមាននៅក្នុងអង្គជំនុំជម្រះសាលាដំបូងនៅ អ.វ.ត.ក។ ដោយសារសាលាដំបូងត្រូវបានអនុញ្ញាតឲ្យអនុវត្តការឃុំខ្លួន ដូច្នេះជាការសមហេតុផល ដែលតុលាការនេះ ត្រូវបានអនុញ្ញាតឲ្យអនុវត្តនូវវិធានការដែលពុំសូវរិតត្បិត។ ការបកស្រាយបែបនេះ មានលក្ខណៈសមស្របទៅនឹងវិធាន ៨២(២) នៃវិធានផ្ទៃក្នុង ដែលបានអនុញ្ញាតឲ្យអង្គជំនុំជម្រះសាលាដំបូង បង្គាប់"ឲ្យដោះលែងដោយដាក់ក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ" ទោះបីជាពុំមានបទប្បញ្ញត្តិចែងអំពីលក្ខខណ្ឌនៃការត្រួតពិនិត្យតាមផ្លូវតុលាការនៅក្នុងមាត្រា ៣០៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាក៏ដោយ។ គួរកត់សម្គាល់ផងដែរថា ពាក្យពេចន៍ "ដីកាសម្រេចឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ" ដែលត្រូវបានកំណត់និយមន័យនៅក្នុងសន្ទានុក្រមនៃវិធានផ្ទៃក្នុង និងត្រូវបានប្រើប្រាស់ក្នុងវិធាន ៦៥ នៃវិធានផ្ទៃក្នុងនោះ រួមបញ្ចូលនូវវិធានការផ្សេងៗ ដែល

[111] សាលដីកាលើបណ្តឹងសាទុក្ខភ្លាមៗ របស់ខៀវ សំផន ចំពោះការស្នើសុំឲ្យនៅក្រៅឃុំ ថ្ងៃទី ៦ ខែ មិថុនា ឆ្នាំ ២០១១ E50/3/1/4កថាខណ្ឌ ៥៦។

[112] សេចក្តីសម្រេចដែលរងការជំទាស់ កថាខណ្ឌ ៧៥។

[113] ចម្លើយតប កថាខណ្ឌ ។

00759906



អាចដាក់លើជនជាប់ចោទជំនួសឱ្យការឃុំខ្លួន រួមទាំងការបង្គាប់នានាតាមមាត្រា ២២៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា។

៤៦ ហេតុដូច្នេះ អង្គជំនុំជម្រះតុលាការកំពូល យល់ឃើញថា មានមូលដ្ឋានគតិយុត្តនៅក្នុងច្បាប់កម្ពុជាសម្រាប់ការត្រួតពិនិត្យតាមផ្លូវតុលាការនៅក្នុងដំណាក់កាលជំនុំជម្រះ។ តុលាការនេះអាចដាក់លក្ខខណ្ឌលើការត្រួតពិនិត្យតាមផ្លូវតុលាការ ដោយរួមបញ្ចូល ប៉ុន្តែ មិនកម្រិតត្រឹម ការទទួលយក "ការត្រួតពិនិត្យផ្នែកវេជ្ជសាស្ត្រ និង/ឬ ការព្យាបាល ដោយស្ថិតក្រោមការតាមដានផ្នែកវេជ្ជសាស្ត្រនៅក្នុងមន្ទីរពេទ្យ"[114]។ ប៉ុន្តែ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា ការដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ មិនអនុញ្ញាតឱ្យមានការឃុំខ្លួនដោយបង្ខំនៅក្នុងមន្ទីរពេទ្យ ឬទីកន្លែងប្រហាក់ប្រហែល សម្រាប់អំឡុងពេលនៃការត្រួតពិនិត្យតាមផ្លូវតុលាការនោះទេ។ ដូចដែលមានចែងច្បាស់លាស់នៅក្នុងមាត្រា ២២៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាថា ការត្រួតពិនិត្យតាមផ្លូវតុលាការ មានអានុភាពក្នុងការដាក់លក្ខខណ្ឌមួយ ឬច្រើនលើសេរីភាពរបស់ជនជាប់ចោទ ដែលលក្ខខណ្ឌនេះអាចរួមបញ្ចូលនូវការកម្រិតមួយចំនួនលើសេរីភាព ប៉ុន្តែ មិនមែនជាការដាក់ក្នុងមន្ទីឃុំឃាំងនោះទេ។ ប្រហាក់ប្រហែលទៅនឹងការដាក់លក្ខខណ្ឌនេះដែរ ការត្រួតពិនិត្យតាមផ្លូវតុលាការ តម្រូវឱ្យមានការសហការពីជនជាប់ចោទ ហើយប្រសិនបើជនជាប់ចោទខកខានក្នុងការអនុវត្ត ការត្រួតពិនិត្យតាមផ្លូវតុលាការ អាចត្រូវបានបដិសេចចោល ហើយបង្គាប់ឱ្យឃុំខ្លួនវិញ[115]។ ប្រសិនបើជនជាប់ចោទមិនមានកាយសម្បទាក្នុងការជ្រើសរើសដោយសេរីក្នុងការទទួលយកការព្យាបាលនៅមន្ទីរពេទ្យនោះទេ វិធានការដែលយកមកអនុវត្តនោះ គឺជាការឃុំខ្លួន មិនមែនការត្រួតពិនិត្យតាមផ្លូវតុលាការនោះទេ។

៤៧ ទោះបីជាការត្រួតពិនិត្យតាមផ្លូវតុលាការ គឺជាជម្រើសមួយនៅក្នុងរឿងក្តីនេះក៏ដោយ ក៏ពុំមានការលើកឡើងពីបញ្ហានេះនៅក្នុងសេចក្តីសម្រេចដែលរងការជំទាស់ ដែលនឹងជួយដល់អង្គជំនុំជម្រះតុលាការកំពូលក្នុងការកំណត់ពីបញ្ហាថាតើ មានមូលដ្ឋានអង្គហេតុ ក្នុងការអនុវត្តការត្រួតពិនិត្យតាមផ្លូវតុលាការ ដែរឬយ៉ាងណា។ ហេតុដូច្នេះ អង្គជំនុំជម្រះតុលាការកំពូល ពុំមានមធ្យោបាយក្នុងការកំណត់ច្បាស់លាស់ពីបញ្ហាថាតើ ជនជាប់ចោទមានឆន្ទៈ និងលទ្ធភាព (ដោយពិចារណាលើភាពពុំមានសម្បទាក្នុងការយល់ការចងចាំដែលបានបង្ហាញដោយអង្គជំនុំជម្រះសាលាដំបូង) ក្នុងការទទួលយកកាតព្វកិច្ចមួយក្នុងចំណោមនោះ នៅក្នុងអំឡុងពេលនៃការដាក់ឱ្យស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ដូចមានចែងក្នុងមាត្រា

[114]មាត្រា ២២៣(១) នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា។

[115]វិធាន ៦៥(៦) នៃវិធានផ្ទៃក្នុង អ.វ.ត.ក និងមាត្រា ២៣០ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា។

00759907



២២៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា។ លើសពីនេះទៀត សេចក្តីថ្លែងការណ៍របស់ជនជាប់ចោទដែលថា ខ្លួនមានឆន្ទៈទទួលយកកាតព្វកិច្ចបែបនេះ មិនមានលក្ខណៈគ្រប់គ្រាន់នោះទេ ប្រសិនបើពិចារណាអំពីលក្ខខណ្ឌនៃភាពមិនមានសមត្ថភាពស្មារតី របស់ជនជាប់ចោទ។ ក្នុងការធានាឱ្យបានថាជនជាប់ចោទអាចបំពេញកាតព្វកិច្ចរបស់ខ្លួនទាក់ទិននឹងការត្រួតពិនិត្យតាមផ្លូវតុលាការ ចាំបាច់ត្រូវតែមានការធានាពីបុគ្គលដែលមានទំនាក់ទំនងជិតស្និទ្ធជាមួយនឹងជនជាប់ចោទ និងអ្នកដែលមានឆន្ទៈជួយដល់ជនជាប់ចោទជំនះនឹងភាពមិនមានសមត្ថភាពស្មារតី ដើម្បីធានាការបំពេញកាតព្វកិច្ចនេះ ជំនួសជនជាប់ចោទ និងដើរតួនាទីជាអ្នកជំនួស។ ឧបសគ្គមួយផ្សេងទៀត ក្នុងការអនុវត្តការដាក់ឱ្យស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ គឺការព្រួយបារម្ភពីសុវត្ថិភាព ព្រមទាំងភាពចាំបាច់សម្រាប់អង្គជំនុំជម្រះសាលាដំបូងក្នុងការវាយតម្លៃពីកម្រិតនៃការគំរាមកំហែងប្រឆាំងនឹងជនជាប់ចោទ និងការសម្រេចពីវិធានការសន្តិសុខដែលមានលក្ខណៈសមស្រប។ ក្នុងករណីដែលមិនមានការបង្ហាញឱ្យឃើញថាលក្ខខណ្ឌទាំងនេះត្រូវបានបំពេញនោះទេ អង្គជំនុំជម្រះតុលាការកំពូល មិនអាចអនុវត្តនូវការត្រួតពិនិត្យតាមផ្លូវតុលាការបានឡើយ។

៤៨ អលទ្ធភាពរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងការកំណត់ពីបញ្ហាថាតើ លក្ខខណ្ឌតម្រូវផ្នែកស្មារតីសម្រាប់ការដាក់ឱ្យស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ អាចត្រូវបានបំពេញដោយជនជាប់ចោទដែរ ឬយ៉ាងណានោះ មិនបានគាំទ្រដល់សំអាងហេតុពីដំបូងរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា ការបន្តឃុំខ្លួនជនជាប់ចោទ គឺត្រូវបានធានាថាជា ប្រយោជន៍ក្នុងការ "ធានានូវវត្តមានរបស់ជនជាប់ចោទក្នុងពេលដំណើរការនីតិវិធី"។ សំអាងហេតុនេះ ពុំមានលក្ខណៈរឹងមាំដោយសារការមិនមានសមត្ថភាពក្នុងការចងចាំរបស់ជនជាប់ចោទដែលនៅក្នុងបរិបទនៃការដោះលែងដោយមានលក្ខខណ្ឌ ឬការដាក់ឱ្យស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ អាចរារាំងជនជាប់ចោទមិនឱ្យចងចាំថាខ្លួនបានយល់ព្រមទៅនឹងលក្ខខណ្ឌនៃការដោះលែង ហើយនៅក្នុងបរិបទនៃការដោះលែងដោយគ្មានលក្ខខណ្ឌវិញ អាចធ្វើឱ្យជនជាប់ចោទទទួលការគំរាមកំហែងចំពោះសន្តិសុខផ្ទាល់ខ្លួន។ យោងតាមសំអាងហេតុខាងលើ ការបន្តឃុំខ្លួនមានលក្ខខណៈចាំបាច់ រហូតដល់អង្គជំនុំជម្រះសាលាដំបូងបង្ហាញថាការព្រួយបារម្ភខាងលើបានចុះថយ។

### ៦.២.៤ រយៈពេលនៃវិធានការ:

៤៩ អង្គជំនុំជម្រះតុលាការកំពូល កត់សម្គាល់អំពីអនុសាសន៍របស់សាស្ត្រាចារ្យ Campbell ឱ្យសាកល្បងប្រើថ្នាំ Donepezil សម្រាប់រយៈពេលបីខែ[116]។ ទោះបីជាអង្គជំនុំជម្រះតុលាការកំពូល មិនមាន...

[116] របាយការណ៍តាមដានរបស់អ្នកជំនាញ រោគមនុស្សចាស់ កថាខណ្ឌ ៨(ii)។

គ្រប់គ្រាន់ក្នុងការស្វែងយល់អំពីអនុសាសន៍តាមការផ្តួចផ្តើមគំនិតរបស់ខ្លួនក៏ដោយ ក៏អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា ឯកសារវេជ្ជសាស្ត្របានណែនាំការសាកល្បងប្រើថ្នាំ[117]រយៈពេល០៦(ប្រាំមួយ)ខែ ដែរ។ ដើម្បីឱ្យមានតុល្យភាព អង្គជំនុំជម្រះតុលាការកំពូលបង្គាប់ឱ្យអង្គជំនុំជម្រះសាលាដំបូងរៀបចំការព្យាបាលតាមអនុសាសន៍របស់អ្នកជំនាញវេជ្ជសាស្ត្រ ហើយត្រូវត្រួតពិនិត្យឡើងវិញក្នុងរយៈពេល០៦(ប្រាំមួយ)ខែ ដែលជារយៈពេលគ្រប់គ្រាន់ក្នុងការសម្រេចពីបញ្ហាថាតើ មានក្តីសង្ឃឹមដែលសមហេតុផលមួយ ដែលជនជាប់ចោទនឹងទទួលបាននូវសម្បទាឡើងវិញដើម្បីចូលរួមសវនាការក្នុងពេលឆាប់ៗខាងមុខ។ ទាក់ទិននឹងការបន្តការឃុំខ្លួន គឺតម្រូវឱ្យមានការពិនិត្យឡើងវិញដោយអនុលោមតាមវិធាន ៨២ នៃវិធានផ្ទៃក្នុង ស្របតាមគោលការណ៍ទូទៅនានា។

## ៧.ផ្នែកសម្រេចសេចក្តី

**ទទួលយក** បណ្តឹងសាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញាយោងតាមវិធាន ១០៤(៤)(ខ)នៃវិធានផ្ទៃក្នុង។

**បដិសេធ** សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងត្រង់ចំណុចបង្គាប់ឱ្យដោះលែងជនជាប់ចោទចេញពីមន្ទីរឃុំឃាំងនៃ អ.វ.ត.ត រួមទាំងចំណុចដែលអង្គជំនុំជម្រះសាលាដំបូងជម្រាបទៅសហព្រះរាជអាជ្ញាថាសហព្រះរាជអាជ្ញាត្រូវបង្កើតយន្តការត្រួតពិនិត្យស្ថានភាពសុខភាពរបស់ជនជាប់ចោទជាប្រចាំ។

**បង្គាប់ថា** អង្គជំនុំជម្រះសាលាដំបូង:

(១) ដោយមានការពិភាក្សាជាមួយអ្នកជំនាញវេជ្ជសាស្ត្រសមស្រប ត្រូវស្នើឱ្យមានការព្យាបាលបន្ថែមដល់ជនជាប់ចោទដែលអាចជួយឱ្យសុខភាពផ្នែកស្មារតីរបស់ជនជាប់ចោទបានប្រសើរឡើង ដើម្បីឱ្យជនជាប់ចោទអាចមានសម្បទាចូលរួមសវនាការបាន ហើយដែលការព្យាបាលនេះត្រូវតែធ្វើឡើងនៅក្នុងមន្ទីរពេទ្យ ឬកន្លែងសមស្របដទៃទៀត នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយស្ថិតនៅក្នុងការចំណាយរបស់ អ.វ.ត.ក។

117 Bengt Winblad *et al.*," វិធីព្យាបាល Donepezil ចំពោះអ្នកជម្ងឺ Alzheimer ធ្ងន់ធ្ងរ៖ ការសិក្សារ ដោយមានការត្រួតពិនិត្យទៅលើសារធាតុរំញោចចិត្ត ចំពោះក្រុមដូចគ្នា ហើយមានលក្ខណៈចៃដន្យ។

(២) ដោយអនុលោមតាមវិធាន៣២ នៃវិធានផ្ទៃក្នុង ត្រូវបង្គាប់ឱ្យជនជាប់ចោទទទួលការត្រួតពិនិត្យពីអ្នកជំនាញផ្នែកវេជ្ជសាស្ត្រ ផ្នែកវិកលចរិត និង/ឬផ្នែកចិត្តសាស្ត្រ ដើម្បីកំណត់បញ្ហាថាតើ ជនជាប់ចោទមានសម្បទាចូលរួមសវនាការបាន ដែរ ឬយ៉ាងណា។ ការត្រួតពិនិត្យផ្នែកវេជ្ជសាស្ត្រនេះ ត្រូវធ្វើឡើងមិនឱ្យលើសពីរយៈពេល ០៦(ប្រាំមួយ)ខែ ចាប់គិតពីពេលចាប់ផ្ដើមការព្យាបាលតាមចំណុចទី១ ខាងលើ។

(៣) ត្រូវសម្រេចដោយមិនមានការពន្យាពេលអំពីស្ថានភាពសម្បទាចូលរួមសវនាការរបស់ជនជាប់ចោទជាបន្ទាន់ បន្ទាប់ពីទទួលបានរបាយការណ៍របស់អ្នកជំនាញ ដែលបានធ្វើការត្រួតពិនិត្យយោងតាមការសម្រេចចំណុចទី២ខាងលើ។

(៤) ត្រូវចាត់ឱ្យមានការឃុំខ្លួនជនជាប់ចោទនៅក្នុងមន្ទីរពេទ្យ ឬកន្លែងសមស្របដទៃទៀតដែលកំណត់ដោយអង្គជំនុំជម្រះសាលាដំបូង។

(៥) ត្រូវឃុំខ្លួនជនជាប់ចោទជាបណ្ដោះអាសន្ននៅក្នុងមន្ទីរឃុំឃាំងនៃ អ.វ.ត.ក រហូតដល់ពេលដែលការរៀបចំចាំបាច់នានាសម្រាប់ការចាប់ផ្ដើមការព្យាបាលខាងលើ ត្រូវបានបំពេញរួចរាល់។

**បង្គាប់**ឱ្យការិយាល័យរដ្ឋបាលផ្ដល់ការគាំទ្រផ្នែករដ្ឋបាលចាំបាច់ សម្រាប់ការអនុវត្តសេចក្ដីសម្រេចនេះ។

ចៅក្រម Chandra Nihal JAYASINGHE ដាក់យោបល់ជំទាស់។

**រាជធានីភ្នំពេញ ថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១១**

**ប្រធានអង្គជំនុំជម្រះតុលាការកំពូល**

**គង់ ស្រឹម**